ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានគោលនយោបាយ

អត្ថបទស្រាវជ្រាវ

# បញ្ហាប្រឈម និងឱកាសរបស់និស្សិតនារីនៅកម្រិតឧត្តមសិក្សា

ឡាយ សុវិជ្ជា*[១] បូ ច័ន្ទគុលិកា[២] ស៊ុក សុផល[៣] ស៊ិន ណារី[៤]

[១ ២ ៣ ៤]នាយកដ្ឋានគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា

*អ៊ីម៉ែលរបស់អ្នកនិពន្ធ៖ sovichea_lay@yahoo.com

បានទទួល៖ កក្កដា ២០២២ សម្រេចយក៖ តុលា ២០២២

## មូលន័យសង្ខេប

ក្រៅពីធម្មជាតិបង្កើត អ្វីៗសុទ្ធតែមនុស្សបង្កើតទាំងអស់ ហើយគុណភាពអ្វីៗទាំងអស់គឺអាស្រ័យលើគុណភាពធនធានមនុស្ស ហើយគុណភាពធនធានមនុស្សត្រូវផ្សារភ្ជាប់ទៅនឹងការអប់រំ ហើយការកសាងគុណភាពការអប់រំគឺជាអ្វីដែលប្រទេសនៅលើសកលលោកកំពុងតែធ្វើ និងប្រឹងប្រែងធ្វើ។ នៅពេលមានការអប់រំល្អ មនុស្សគ្រប់រូបសុទ្ធតែជាធនធានដែលសង្គមត្រូវការ។ ពួកគេនឹងមានសមត្ថភាពពេញលេញក្នុងការអភិរក្ស ការពារ និងអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយវិបុលភាព។ នៅក្នុងការសិក្សានេះ យើងធ្វើការសិក្សាអំពីបញ្ហាប្រឈម និងឱកាសរបស់និស្សិតនារីកំពុងសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា ដែលត្រូវចាកឆ្ងាយពីឪពុកម្ដាយ ឬក៏មកតាមបណ្ដាស្រុក/ខេត្តនានា ដោយប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ ក្នុងការប្រមូលទិន្នន័យ។ តាមលទ្ធផលស្រាវជ្រាវបង្ហាញថាទន្ទឹមនឹងទទួលបានឱកាស និស្សិតនារីក៏មានបញ្ហាប្រឈមជាច្រើនក្នុងអំឡុងពេលសិក្សា ដូចជា កង្វះអាហារូបត្ថម្ភ កង្វះអគារអន្តេវាសិកដ្ឋាន និងការថែទាំអនាម័យក្នុងបន្ទប់ ការទទួលរងបន្ទុកគ្រួសារ បញ្ហាសុខភាព កង្វះសេវាផ្ដល់ប្រឹក្សាក្នុងសាលា។ ដើម្បីដោះស្រាយបញ្ហាជីវភាពក្នុងអំឡុងពេលរៀនសូត្រ និស្សិតនារីជាច្រើនបានអនុវត្តគំរូ "រៀនបណ្ដើរ ធ្វើការបណ្ដើរ" រហូតដល់មាននិស្សិតមួយចំនួនអាចឈានទៅដល់ការផ្ញើប្រាក់ជូនក្រុមគ្រួសារថែមទៀតផង។ ឧបសគ្គចម្បងដែលបង្កឱ្យសិស្សនារីបោះបង់ការសិក្សាគឺកត្តាជីវភាពក្រីក្រតែម្តង ដូច្នេះការកាត់បន្ថយភាពក្រីក្រ ក៏មានន័យថាការចូលរួម

លើកកម្ពស់គុណភាពអប់រំដល់សិស្សនារីដែរ។ ទឹកចិត្តគ្រូបង្រៀនក៏ដើរតួយ៉ាងសំខាន់ដូចនឹងពាក្យថា "គ្រូបង្រៀនជាវិស្វករព្រលឹង" ក្នុងការបណ្ដុះស្មារតី ការលើកទឹកចិត្ត និងការទំនុកបម្រុងក្នុងដំណើរភាពជោគជ័យនៃការសិក្សារបស់សិស្សនារីដែរ នៅពេលនិស្សិតមានបញ្ហាប្រឈមនៃភាពអស់សង្ឃឹម និងការបាក់ទឹកចិត្តនៃការសិក្សា។

ជាសន្និដ្ឋានរួម កាលណាកម្រិតជីវភាពឪពុកម្ដាយកាន់តែលំបាក និស្សិតនារីនឹងទទួលរងផលប៉ះពាល់ពីសម្ពាធគ្រួសារកាន់តែធ្ងន់ ហើយចុងក្រោយអាចឈានទៅរកការបោះបង់សិក្សា។ ភាពក្រីក្រគឺជារនាំងនៃការទទួលបានសិទ្ធិការអប់រំពេញលេញ ដូចនេះការលុបបំបាត់ភាពក្រីក្រ ក៏ជាការបើកទីលំហរនៃការអភិវឌ្ឍធនធានមនុស្សសម្រាប់មនុស្សគ្រប់រូបក្នុងការទទួលសិទ្ធិការអប់រំពេញលេញ។

**ពាក្យគន្លឹះ៖** និស្សិតនារី ឧត្តមសិក្សា បញ្ហាប្រឈម សាកលវិទ្យាល័យ អាហារូបករណ៍

**អាគតដ្ឋាន៖** ឡាយ, ស., បូ, ច., ស៊ុក, ស., & ស៊ិន, ណ. (២០២២). បញ្ហាប្រឈម និងឱកាសរបស់និស្សិតនារីនៅកម្រិតឧត្តមសិក្សា, *កាលិកបត្រអប់រំកម្ពុជា.* ៥(២), ៥៦-៨៤។

## ១. សេចក្ដីផ្ដើម

ការអប់រំ គឺជាកត្តាចាំបាច់បំផុតសម្រាប់មនុស្សជាតិ ការអប់រំមិនត្រឹមតែបង្រៀនមនុស្សឱ្យក្លាយជាមនុស្សរឹងមាំ ថែមទាំងផ្ដល់ការរស់នៅដ៏មានតម្លៃមួយក្នុងសង្គម ហើយការអប់រំក៏ជាកត្តាដ៏មានប្រសិទ្ធភាពមួយដែលអាចជានាមនុស្សឱ្យរួចផុតពីភាពក្រីក្រ។ មនុស្សដែលមានការអប់រំខ្ពស់ គឺរស់នៅប្រកបដោយគំនិតបង្កើតថ្មី ស្មារតីទទួលខុសត្រូវ ឯករាជ្យភាព ស្នេហាភាព និងយុត្តិធម៌ចំពោះប្រទេសជាតិ។ នៅពេលមានការអប់រំល្អ មនុស្សនឹងមានសមត្ថភាពពេញលេញក្នុងការដឹកនាំ អភិរក្ស ការពារ និងអភិវឌ្ឍន៍ប្រទេសជាតិ។ ហេតុនេះហើយបានជាប្រទេសនីមួយៗ បានបោះទុនធនធានជាច្រើន និងបានខិតខំប្រឹងប្រែងអភិវឌ្ឍការអប់រំចំពោះជាតិសាសន៍ខ្លួន ដើម្បីកសាងពួកគេឱ្យក្លាយជាធនធានមួយដ៏មានតម្លៃចំពោះការលះបង់សម្រាប់សង្គមជាតិ។ ទោះបីយ៉ាងណា បើយើងក្រឡេកមើលតថភាពវប្បធម៌សង្គមជាសកលលោកវិញរមែងតែងតែយកចិត្តទុកដាក់ និងគាំទ្រផ្ដល់ការអប់រំដល់មនុស្សប្រុសច្រើនជាងមនុស្សស្រី ផ្ដល់អាទិភាពមនុស្សប្រុសរៀនសូត្រខ្ពស់ជាងមនុស្សស្រី ហេតុនេះហើយបានជាជំរុញឱ្យកើតមាននៅវិសមភាពយេនឌ័រក្នុងការទទួលបានការអប់រំ ជាពិសេសនោះ នៅក្នុងកម្រិតថ្នាក់ឧត្តមសិក្សានិងក្រោយឧត្តមសិក្សា និងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍តែម្ដង ដូចជា ប្រទេសអារ៉ាប់ ប្រទេសអាស៊ីអាគ្នេយ៍ជាដើម (UNESCO, 2007)។ ទោះបីជាសកលលោកទទួលស្គាល់ថា ចំនួនមនុស្សស្រី ច្រើនជាងមនុស្សប្រុស តែកម្រិតនៃការទទួលបានការអប់រំមានចំនួនមនុស្សប្រុសច្រើនជាង

មនុស្សស្រី ដូចតាមការគូសបញ្ជាក់ដែលបានរកឃើញថា ពីរភាគបីនៃចំនួនមនុស្សស្រី គឺមិនចេះអានអក្សរ (UNDP, 2009)។

ក្នុងអាណត្តិទី៦ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងគោលដៅលើកកម្ពស់គុណភាពអប់រំ និងផ្តល់ឱកាសដល់ប្រជាពលរដ្ឋទូទៅទទួលបានការអប់រំប្រកបដោយសមភាព សមធម៌ និងសិក្សាពេញមួយជីវិត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ទន្ទឹមនឹងនោះដែរ ចតុកោណទី១ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ស្តីពីការអភិវឌ្ឍធនធានមនុស្ស ដែលមុំទី៤ មានគោលដៅយុទ្ធសាស្ត្រ ពង្រឹងសមត្ថភាពយេនឌ័រនិងការគាំពារសង្គម ក្នុងគោលបំណងលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច ជាពិសេសពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។ ជាលទ្ធផល រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធិផលជាអាទិ៍៖ បានបញ្ជ្រាបយេនឌ័រក្នុងក្របខ័ណ្ឌគោលនយោបាយនិងផែនការអភិវឌ្ឍជាតិ បានកាត់បន្ថយគម្លាតក្នុងវិស័យអប់រំបានបណ្តុះបណ្តាលវិជ្ជាជីវៈ មុខងារសាធារណៈ បានពង្រីកសហគ្រិនភាពរបស់ស្ត្រី បានកាត់បន្ថយអំពើហិង្សានិងការរំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ បានលើកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ព្រមទាំងពង្រីកកិច្ចការពារផ្លូវច្បាប់ដល់ស្ត្រីនិងកុមារ។ ទោះបីយ៉ាងណា កម្ពុជាក៏នៅមានបញ្ហាប្រឈមមួយចំនួនជាអាទិ៍៖ ការរើសអើងលើស្ត្រីនៅតែមាន បន្ទុកការងារនិងគ្រួសារនៅតែរាំងឱកាសស្ត្រីក្នុងការអប់រំ សេដ្ឋកិច្ច សង្គម និងនយោបាយ ការជួញដូរនិងអំពើហិង្សាលើស្ត្រីនិងកុមារនៅបន្តកើតមាន ពិសេសចំពោះស្ត្រីចំណាកស្រុក វិសាលភាពគ្របដណ្តប់នៃកម្មវិធីជាតិជំនួយសង្គមនិងរបបសន្តិសុខសង្គមនៅមិនទាន់ទូលំទូលាយ និងពេញលេញ និងដំណើរការគ្រប់គ្រងកម្មវិធី របបនៃប្រព័ន្ធគាំពារសង្គមនៅមិនទាន់មានលក្ខណៈប្រមូលផ្តុំ។

ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតឡើងនូវសកម្មភាពអន្តរាគមន៍លើកកម្ពស់ការអប់រំសិស្សនារីគ្រប់កម្រិតសិក្សាដើម្បីឆ្លើយតបទៅនឹងគោលនយោបាយអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ឆ្នាំ២០៣០។ ទោះជាមានអន្តរាគមន៍ជាច្រើនក៏ដោយ ក៏អត្រានៃការចុះឈ្មោះចូលរៀនរបស់សិស្សនារី នៅកម្រិតឧត្តមសិក្សាមានអត្រាទាបជាងចំណុចដៅដែលកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅឡើយ និងមានការធ្លាក់ចុះជាច្រើននៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។

នៅក្នុងការសិក្សានេះ អ្នកស្រាវជ្រាវនឹងធ្វើការសិក្សាដោយសង្កត់ធ្ងន់ទៅលើបញ្ហាប្រឈមនិងឱកាសនានានៃនិស្សិតនារីដែលកំពុងសិក្សានៅតាមគ្រឹះស្ថានសាធារណៈ និងឯកជនក្នុងកម្រិតថ្នាក់ឧត្តមសិក្សា

ដើម្បីឈ្វេងយល់អំពីសុខមាលភាពសុខភាពសិក្សា ជីវភាពរស់នៅ ព្រមទាំងការទំនាក់ទំនងជាមួយសាកលវិទ្យាល័យនិងសហគមន៍ដែលនិស្សិតនារីរស់នៅក្នុងអំឡុងពេលសិក្សា។

## ២. ការស្រាវជ្រាវពីមុនៗទាក់ទងនឹងការសិក្សារបស់សិស្សនារីនៅឧត្តមសិក្សា

ចំពោះកម្រិតថ្នាក់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សា បើគិតពីសមាមាត្រនៃចំនួនមធ្យមភាគនៃការចុះឈ្មោះចូលរៀនរបស់និស្សិតនារីតាមកម្រិតថ្នាក់បរិញ្ញាបត្ររងមាន ៣៣.២៣% បរិញ្ញាបត្រមាន ៤១.១៤% និងបរិញ្ញាបត្រជាន់ខ្ពស់មាន ២១.១១% និងបណ្ឌិតមាន ៥.៤២% (ឆ្នាំសិក្សា ២០០៦ រហូតដល់ ២០១៦) (EMIS, 2016)។ ជាក់ស្តែងនិស្សិតនារីដែលចូលវ័យថ្នាក់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សា ជាវ័យដែលប្រឈម និងងាយរងគ្រោះខ្លាំងបំផុតចំពោះការបន្តការសិក្សា ឬបោះបង់ការសិក្សា ដូចជា កត្តាចម្ងាយផ្លូវ ការបង់ថ្លៃសិក្សា កត្តាជីវភាពសេដ្ឋកិច្ចគ្រួសារ កត្តាកម្រិតវប្បធម៌ឪពុកម្តាយ កត្តាវប្បធម៌សង្គម កត្តាសុវត្ថិភាព កត្តារៀបការនិងបង្កើតគ្រួសារ កត្តាការងារ កត្តាហេដ្ឋារចនាសម្ព័ន្ធសាលា។ល។ ជាទូទៅសិស្សដែលទទួលរងផលប៉ះពាល់បោះបង់ការសិក្សាច្រើនជាងគេ គឺសិស្សដែលមានជីវភាពគ្រួសារក្រីក្រ និងរស់នៅតាមទីជនបទនិងតំបន់ដាច់ស្រយាល ពីព្រោះពួកគេត្រូវធ្វើការបំលាស់ទីចាកឆ្ងាយពីផ្ទះសម្បែង ដើម្បីបន្តការសិក្សាដោយសារមានចំនួនសាកលវិទ្យាល័យលើសលុបស្ថិតនៅតាមទីប្រជុំជន និងទីក្រុង។ ដើម្បីជំរុញការចូលរៀនរបស់និស្សិតនារី និស្សិតក្រីក្រ និងនិស្សិតនៅតាមតំបន់ដាច់ស្រយាល ក្រសួងបានផ្តល់ការលើកទឹកចិត្តជាអាទិភាពតាមរយៈការផ្តល់អាហារូបករណ៍សម្រាប់ពួកគាត់ ដូចជា និស្សិតនារី (១៥%) និស្សិតក្រីក្រ (២០%) និងនិស្សិតនៅតាមតំបន់ដាច់ស្រយាល (៥%) ក្នុងចំណោម១០០%នៃនិស្សិតអាហារូបករណ៍ (ទិន្នន័យឧត្តមសិក្សា ២០១៩-២០២០)។

### ២.១ កត្តាចម្ងាយផ្លូវ

តាមការស្រាវជ្រាវកឃើញថា កត្តាចម្ងាយផ្លូវពីផ្ទះមកសាលាបានធ្វើឱ្យសិស្ស ជាពិសេសសិស្សតាមទីជនបទពិបាកបន្តការសិក្សាទៅមុខទៀត ដោយសារបញ្ហាចម្បងទាក់ទងនឹងការបន្ថែមចំណាយ (Birrel, 2000; William, 1993) ដូចជាការចំណាយជួលកន្លែងស្នាក់នៅ (រួមទាំងថ្លៃទឹក ថ្លៃភ្លើង) ថ្លៃម្ហូបអាហារ ថ្លៃមធ្យោបាយធ្វើដំណើរ និងការចំណាយលើបង់ថ្លៃសិក្សា។ល។ ដូចនេះបើឪពុកម្តាយខ្វះលទ្ធភាពថវិកាគាំទ្រសម្រាប់ការសិក្សា នោះកូនៗនឹងប្រឈមខ្លាំងចំពោះការសម្រេចចិត្តបន្តការសិក្សា។ ទន្ទឹមនឹងនោះដែរ ការធ្វើ ចំណាកស្រុកពីផ្ទះ និងភូមិកំណើតមកបន្តការសិក្សាថ្នាក់ឧត្តមសិក្សា ក៏មានក្តីបារម្ភអំពីសុវត្ថិភាពកូនៗ ដែលកត្តានេះធ្វើឱ្យឪពុកម្តាយមួយចំនួនសម្រេចចិត្តមិនបញ្ជូនកូនទៅសិក្សាបន្តទៀត។ តាមការស្រាវជ្រាវមួយបង្ហាញថា បញ្ហាប្រឈមនៃការចូលរៀនរបស់

សិស្សស្រីនៅកម្រិតឧត្តមសិក្សាមានកម្រិតខ្ពស់ពាក់ព័ន្ធនឹងកត្តាភូមិសាស្ត្រ ជាពិសេស សិស្សស្ថិតនៅតំបន់ភូមិភាគឥសាន និងពាយ័ព្យនៃប្រទេសកម្ពុជា (Patricia Noelle O'Brien, 2004)។

## ២.២ កត្តាជីវភាពសេដ្ឋកិច្ច

ជីវភាពសេដ្ឋកិច្ចគ្រួសារ គឺជាប្រភពធនធានដ៏សំខាន់បំផុតសម្រាប់ការគាំទ្រផ្នែកអប់រំជោគជ័យរបស់កូន ដូចនេះ បើឪពុកម្តាយមិនមានលទ្ធភាពផ្តល់ការផ្គត់ផ្គង់ថវិកា និងខ្វះការគាំទ្រលើកទឹកចិត្តដល់ការសិក្សា នោះកូនៗនឹងត្រូវប្រឈមបន្តការសិក្សា។ តាមការសិក្សាស្រាវជ្រាវមួយដែលធ្វើឡើងនៅក្នុងភូមិមួយនៃស្រុកព្រៃកប្បាស ខេត្តតាកែវ ឆ្នាំ២០១៥ បានបង្ហាញថា "៩៩%នៃក្រុមគ្រួសារក្នុងភូមិគឺសុទ្ធតែកម្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជនទាំងអស់ (កាលនោះ អ្នកភូមិនៅនិយាយថាខ្ចីលុយរដ្ឋ) ហើយចំណែកនៅសល់ ១% ទៀត បើកម្ចីប្រាក់ គឺកម្ចីធំតែម្តង (ដកស្រង់សម្តីលោកមេភូមិ)"។ ភាគច្រើនបំណុលដែលត្រូវសងត្រឡប់ទៅវិញ គឺត្រូវធ្លាក់ទៅលើបន្ទុករបស់កូន ប្រសិនបើកូនមានការងារធ្វើ និងអាចរកចំណូលជូនគ្រួសារបាន។ កូនៗត្រូវមានកាតព្វកិច្ចជួយចែករំលែកបង់រំលស់ប្រាក់កម្ចីប្រចាំខែជូនក្រុមគ្រួសារ។ ត្រង់ចំណុចនេះដែរ ពេលខ្លះពួកគាត់មិនត្រឹមតែមិនអាចមានសមត្ថភាពផ្គត់ផ្គង់ដល់ការសិក្សារបស់កូនប៉ុណ្ណោះទេ ប៉ុន្តែបែរជាផ្តល់បន្ទុកបន្ថែមដល់កូនទៅវិញ។ ដូចដែលសង្គមខ្មែរតែងតែនិយាយតៗគ្នាថា "កូនស្រីចេះគិតគូរគ្រួសារជាងកូនប្រុស ទោះបីកូនក្លាយទៅជាអ្វី ក៏កូនមិនដែលភ្លេចឪពុកម្តាយដែរ" ក្នុងន័យនេះអាចបញ្ជាក់បានថា កូនស្រីមិនអាចយកភ្នែកមើលជីវភាពគ្រួសារក្រលំបាក ខ្វះមុខខ្វះក្រោយ រកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក ឬរកមួយថ្ងៃចាយមួយថ្ងៃបានឡើយ នៅក្នុងខណៈពេលដែលខ្លួនមានកម្លាំងពេញបរិបូរណ៍ ទីផ្សារការងារត្រូវការ និងច្បាប់ទទួលស្គាល់ថែមទៀត។ មិនថាសិស្សនារីធ្លាប់មានប្រវត្តិរៀនពូកែយ៉ាងណា ក៏ត្រូវទុកការសិក្សាមួយអន្លើសិន បែរជាត្រូវប្រឹងរកការងារដោះស្រាយរឿងជីវភាពគ្រួសារ និងចែករំលែកការទទួលខុសត្រូវចិញ្ចឹមសមាជិកគ្រួសារជាមួយឪពុកម្តាយថែមទៀត កត្តានេះមួយប្រហែលជាហេតុផលបញ្ជាក់ថាការចូលរួមសិក្សារបស់សិស្សនារីនៅក្នុងកម្រិតថ្នាក់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សា កាន់តែតិចទៅៗជាលំដាប់។

## ២.៣ អត្រាចុះឈ្មោះចូលរៀនរបស់សិស្សនារីនៅកម្រិតចំណោះទូទៅ

កត្តាដែលសិស្សស្រីចូលរៀននៅកម្រិតឧត្តមសិក្សាតិចក៏បណ្តាលមកពីការផ្លាស់ប្តូរវ័យ និងអត្រាថយចុះនៃការចុះឈ្មោះចូលរៀនពីមួយកម្រិតទៅមួយកម្រិតទៀត (បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ) ទាំងនេះបានជះឥទ្ធិពលដល់ឱកាស សម្រាប់សិស្សស្រីក្នុងការឈានទៅបន្តរៀនថ្នាក់កម្រិតឧត្តមសិក្សា (Patricia Noelle O'Brien, 2004)។ តាមចំនួនមធ្យមភាគនៃការចុះ

ឈ្មោះចូលរៀនបង្ហាញថា សិស្សស្រីនៅកម្រិតថ្នាក់បឋមសិក្សាមាន ៤៧.៦១% អនុវិទ្យាល័យមាន ៤៨.០១% និងវិទ្យាល័យមាន ៤៤.២១% នៅឆ្នាំសិក្សា ២០០៥ រហូតដល់ ២០១៥ (EMIS, 2016)។

តាមស្ថិតិនេះបង្ហាញថា វិសមភាពយេនឌ័រក្នុងការទទួលបានការអប់រំនៅតែកើតមានរវាងបុរស និងនារី ដោយសារយើងសង្កេតឃើញមាន ចំនួនសិស្សនារីចុះឈ្មោះចូលរៀនមានកម្រិតទាបជាងចំនួនសិស្សប្រុសហើយបន្តធ្លាក់ជាបន្តបន្ទាប់ ជាពិសេសនៅពេលសិស្សនារីចាប់ផ្តើមចូលកម្រិតថ្នាក់មធ្យមសិក្សាទុតិយភូមិ។ មូលហេតុនៃការធ្លាក់ចុះនេះ គឺប្រហែលមកពីសិស្សនារីចាប់ផ្តើមចូលវ័យជំទង់ដែលជាវ័យចេះគិតគូរពិចារណាចំពោះជីវភាពសេដ្ឋកិច្ចគ្រួសារដែលកត្តានេះធ្វើឱ្យនារីមានភាពប្រឈម និងងាយរងគ្រោះក្នុងការបោះបង់ការសិក្សា ដើម្បីស្វែងរកការងារធ្វើ និងរកប្រាក់កម្រៃជូនគ្រួសារ។

## ២.៤ កត្តាវប្បធម៌

នៅក្នុងឆ្នាំ២០១៤ មានការស្រាវជ្រាវរបស់សាកលវិទ្យាល័យ ដែនវើ (University of Denver, USA) ស្តីពីការអប់រំ និងយេនឌ័រក្នុងប្រទេសកម្ពុជាបច្ចុប្បន្នបានបង្ហាញថា ស្ត្រីខ្មែរគឺទទួលរងនូវឥទ្ធិពលច្បាប់វប្បធម៌ដែលមានការចាក់ឫសតាំងពីយូរលង់ណាស់មកហើយ ដែលពួកគាត់មិនអាចមានលទ្ធភាពឈានទៅមុខបាន ដូចជា ការចូលសាលារៀន កន្លែងធ្វើការ និងការងារនយោបាយជាដើម។ ច្បាប់រចនាសម្ព័ន្ធនៃប្រទេសកម្ពុជា មានភាពតឹងរឹងចំពោះស្ត្រីក្នុងការបើកឱ្យនិយាយ និងមិននិយាយ (Escamilla, 2011) ដូច្នេះកត្តាវប្បធម៌ ប្រពៃណីក៏ជាកត្តារារាំង និងកាត់បន្ថយចំនួនសិស្សស្ត្រីចូលរៀនក្នុងថ្នាក់ឧត្តមសិក្សាផងដែរ។ នៅក្នុងសង្គមកម្ពុជាគេតែងតែពោលពាក្យថា "ស្ត្រីបង្វិលចង្រ្កានមិនជុំ" "នំមិនធំជាងនាឡិ" "ស្ត្រីកុំចាំបាច់ប្រឹងរៀនខ្ពស់ពេក ពេលមានប្តី ប្តីចិញ្ចឹមហើយ" ជាដើម។ល។

## ៣. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីធ្វើការប្រមូលទិន្នន័យឱ្យបានគ្រប់ជ្រុងជ្រោយនិងស៊ីជម្រៅ ក្រុមអ្នកសិក្សាស្រាវជ្រាវនឹងចុះទៅដល់គោលដៅនៅតាមគ្រឹះស្ថាននានា ដែលបានកំណត់ទុករួចជាស្រេច ដើម្បីធ្វើការសម្ភាសផ្ទាល់មាត់ជាមួយសាកលវិទ្យាធិការ(រង) សាស្ត្រាចារ្យ បុគ្គលិកសិក្សា និងនិស្សិតនារីដែលកំពុងសិក្សានៅក្នុងសាកលវិទ្យាល័យ និងស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន ជាពិសេសនោះទៀត ក្រុមអ្នកសិក្សានឹងបន្តធ្វើការសម្ភាសផ្ទាល់មាត់ជាមួយមន្ត្រីជំនាញ។ សំណាកសាកលវិទ្យាល័យដែលត្រូវជ្រើសរើសយកមកសិក្សាមានចំនួន ១០ គ្រឹះស្ថានរដ្ឋនិងឯកជន(៦គ្រឹះស្ថានស្ថិតនៅតាមបណ្តាខេត្ត និង៤គ្រឹះស្ថានស្ថិតនៅក្នុងរាជធានីភ្នំពេញ)។ សំណាកនិស្សិតដែលត្រូវជ្រើសរើសមានចំនួន ៣១ រូប (៣០ រូប សម្រាប់បំពេញសំណួរ និងមាន ១រូប សម្រាប់ធ្វើសម្ភាស) ក្នុងមួយគ្រឹះស្ថាន ហើយនិស្សិតទាំងនោះ គឺជា

និស្សិតដែលមិនរស់នៅជាមួយឪពុកម្តាយ ឬមកតាមបណ្តាស្រុក/ខេត្តនានា ដើម្បីបន្តការសិក្សាតាមគ្រឹះស្ថានឧត្តមសិក្សា។

លើសពីនេះទៀត ដើម្បីស្វែងយល់ពីជីវិតពិតនៃក្រុមគ្រួសារនិស្សិតនារី ក្រុមអ្នកស្រាវជ្រាវនឹងធ្វើការចុះផ្ទាល់ទៅដល់ស្រុកកំណើតដែលជាទីកន្លែងរស់នៅផ្ទាល់របស់និស្សិត ហើយក្រុមអ្នកស្រាវជ្រាវនឹងធ្វើការសម្ភាសជាមួយឪពុកម្តាយ និងសហគមន៍ ព្រមទាំងធ្វើការសង្កេតតថភាពជាក់ស្តែងនៃការរស់នៅ និងឥរិយាបទរបស់សហគមន៍ចំពោះការសិក្សាជាដើម។ សំណាកដែលត្រូវជ្រើសរើសសម្រាប់ជាករណីសិក្សានេះ មានចំនួន ៤ ករណីផ្សេងគ្នា។ រាល់សំណាកនីមួយៗអាចជ្រើសរើសដោយការចង្អុលបង្ហាញពីសាកលវិទ្យាល័យ ឬក៏ជ្រើសតាមក្រុមអ្នកស្រាវជ្រាវពេលចុះប្រមូលទិន្នន័យ។

ការសិក្សានេះចាប់ផ្តើមចុះប្រមូលទិន្នន័យនៅចុងខែកញ្ញា និងដើមខែតុលា ឆ្នាំ២០១៩ ដូចនេះឧបសគ្គចម្បងបំផុតពេលចុះប្រមូលទិន្នន័យ គឺក្នុងអំឡុងពេលសាលាវិស្សមកាលដែលនិស្សិតមកពីតាមបណ្តាស្រុក/ខេត្តផ្សេងៗភាគច្រើនត្រូវត្រឡប់ទៅលេងស្រុកកំណើតខ្លួនវិញ ដូច្នេះ ដើម្បីប្រមូលបានទិន្នន័យគ្រប់ជ្រុងជ្រោយ ក្រុមការងារត្រូវធ្វើការចុះប្រមូលទិន្នន័យនៅដើមខែវិច្ឆិកាម្តងទៀត។

## ៤. លទ្ធផលស្រាវជ្រាវ

### ៤.១ កង្វះអាហារូបត្ថម្ភ

តាមរយៈនៃការចុះសិក្សាស្រាវជ្រាវបានបង្ហាញថា បញ្ហាប្រឈមដែលលេចធ្លោមួយនៃនិស្សិតនារីមកពីតាមបណ្តាស្រុក/ខេត្តនានា គឺការបរិភោគមិនគ្រប់គ្រាន់ដែលឈានទៅដល់បញ្ហាកង្វះជីវជាតិបំប៉ន ដើម្បីទ្រទ្រង់ដល់ការលូតលាស់សារពាង្គកាយ និងប្រាជ្ញារៀនសូត្រ។ ក្នុងចំណោមនិស្សិតនារីចូលរួមឆ្លើយសំណួរមាន៧២.៨០% បានទទួលស្គាល់ថា ដោយសារបញ្ហាជីវភាពសេដ្ឋកិច្ចគ្រួសារធ្វើឱ្យពួកគាត់មិនមានថវិកាគ្រប់គ្រាន់ ហើយការចំណាយត្រូវសន្សំសំចៃបំផុត។ **តារាងទី១** បង្ហាញអំពីប្រភពប្រាក់ដែលនិស្សិតនារីទទួលបានសម្រាប់ការចំណាយប្រចាំខែ។ តាមទិន្នន័យបញ្ជាក់ច្បាស់ថានិស្សិតនារីមិនពឹងផ្អែកទាំងស្រុងទៅលើប្រភពប្រាក់ឪពុកម្តាយតែមួយមុខទេ ផ្ទុយទៅវិញពួកគាត់ទទួលបានពីប្រភពផ្សេងៗគ្នា ក្នុងនោះដែរប្រភពមួយដែលលេចធ្លោជាងគេបន្ទាប់ពីប្រភពប្រាក់ឪពុកម្តាយ (៥៩.៦%) គឺអាចរកការងារចិញ្ចឹមជីវិតដោយខ្លួនឯងបាន (១៧.៤%)។ ចំណែក **តារាងទី២** បង្ហាញអំពីមូលហេតុនៃការចំណាយមិនគ្រប់គ្រាន់សម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃសម្រាប់និស្សិតនារី។ តាមទិន្នន័យបង្ហាញថា កត្តាចម្បងដែលធ្វើឱ្យការចំណាយមិនគ្រប់រួមមាន៖ គ្រួសារក្រីក្រ ទំនិញថ្លៃ សម្ភារៈសិក្សាថ្លៃ ថ្លៃបង់សាលាថ្លៃ ការស្នាក់នៅថ្លៃ។ ក្នុងចំណោមនោះដែរ មាននិស្សិតនារី ២៦.៦៥% បានត្អូញត្អែរអំពីទំនិញថ្លៃ។

អ្វីដែលគួរឱ្យកត់សម្គាល់មួយ គឺលើការបរិភោគចំណីអាហារ ម្ហូបអាហារដែលពួកគាត់បរិភោគគឺ ដើម្បីឆ្អែតតែប៉ុណ្ណោះ ដោយមិនមានផ្ទុកនៅសារជាតុបំប៉នគ្រប់គ្រាន់នោះឡើយ។ តាមរយៈការសម្ភាស មាននិស្សិតនារីម្នាក់បានឆ្លើយដោយទឹកមុខយ៉ាងក្រៀមក្រំថា "ពេលខ្លះដោយសារមិនមានលុយ ខ្ញុំត្រឹម ផឹកទឹកធ្វើជាអាហារតែប៉ុណ្ណោះ ភាគច្រើនអាហារប្រចាំថ្ងៃរបស់ខ្ញុំ គឺយកមកពីផ្ទះ ដូចជា អង្ករ ប្រហុក ផ្អក និងត្រីងៀតជាដើម"។

មុននឹងឈានទៅរកប្រាជ្ញាវាងវៃទៅបាន ដំបូងមនុស្សត្រូវការកាយសម្បទាល្អលូតលាស់ពេញលេញ កម្លាំងមាំមួន និងសុខភាពល្អជាមុនសិន។ ជាលក្ខណៈបច្ចេកទេសនៃរបបអាហារដើម្បីធានាឱ្យបាននូវ សុខភាពល្អ ប្រជាពលរដ្ឋទូទៅគួរបរិភោគអាហារឱ្យបានយ៉ាងតិចបំផុត ២៥ មុខក្នុងមួយសប្ដាហ៍ក្នុង នោះរួមមាន៖ គ្រាប់ធុញ្ញជាតិ (ស្រូវ ពោត) បន្លែផ្លែឈើ សត្វសាច់ក្រហម (សាច់គោ សាច់ជ្រូក) សត្វ សាច់ស (មាន់ ទា) ត្រី ទឹកដោះគោ ទឹកសណ្ដែក គ្រាប់ប្រេង (គ្រាប់ស្វាយចន្ទី គ្រាប់កៅឡាក់) ពពួក ឬស (ដំឡូង) និងផ្សេងៗ (Shanshan Wang, 2016)។ បើយើងប្រៀបធៀបគ្នារវាងលក្ខណៈ បច្ចេកទេសនៃរបបអាហារ និងការបរិភោគនៃនិស្សិតនារីម្នាក់នេះ គឺខុសគ្នាដូចមេឃនិងដី កត្តានេះ ហើយអាចធ្វើឱ្យយើងសន្និដ្ឋានបានថា របបអាហាររបស់គាត់នៅមិនទាន់បំពេញតម្រូវការនៃការលូត លាស់សារពាង្គកាយ និងបញ្ញាស្មារតីពេញលេញរបស់គាត់នៅឡើយ។ យោងតាមការស្រាវជ្រាវ ដើម្បី ចៀសផុតពីជំងឺខ្វះជីវជាតិនិងលើសថាមពល មនុស្សគ្រប់រូបត្រូវបានជំរុញការបរិភោគអាហារឱ្យបាន ច្រើនមុខ ដោយផ្អែកតាមគុណភាពជីវជាតិអាហារ ព្រមទាំងរក្សាសកម្មភាពលំហាត់ប្រាណជាប្រចាំថ្ងៃ ផងដែរ ដើម្បីលើកកម្ពស់សុខភាពរស់នៅ (Shanshan Wang, 2016)។

**តារាងទី១៖ បង្ហាញអំពីប្រភពចំណាយប្រចាំខែរបស់និស្សិតនារីក្នុងអំឡុងពេលសិក្សា** (**n** = 276)

| **ប្រភពនៃប្រាក់ចំណាយប្រចាំខែ** | **ភាគរយ (%)** |
|---|---|
| ឪពុកម្ដាយ | 59.6 |
| បងប្អូនបង្កើត | 12.1 |
| សាច់ញាតិ | 5.0 |
| អាហារូបករណ៍ពីសាលា / អង្គការក្រៅរដ្ឋាភិបាល | 5.8 |
| ការងារផ្ទាល់ខ្លួន | 17.4 |

**តារាងទី២៖ ទិន្នន័យបង្ហាញអំពីហេតុផលនៃការចំណាយមិនគ្រប់គ្រាន់សម្រាប់ការសិក្សា និងការរស់នៅនៃនិស្សិតនារី** ( **n** = 276 )

| **ការចំណាយមិនគ្រប់គ្រាន់សម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃ** | **ភាគរយ (%)** |
|---|---|
| គ្រួសារក្រីក្រ | 33.51 |
| ទំនិញថ្លៃ | 26.65 |
| ការស្នាក់នៅថ្លៃ | 11.61 |
| សម្ភារសិក្សាថ្លៃ | 15.83 |
| ថ្លៃបង់សាលាថ្លៃ | 12.40 |

## ៤.២ កង្វះអគារអន្តេវាសិកដ្ឋាន និងការថែទាំអនាម័យក្នុងបន្ទប់

អគារអន្តេវាសិកដ្ឋាន គឺជាផ្ទះទី២ដែលផ្តល់ភាពកក់ក្តៅ សុខសុវត្ថិភាព និងទំនុកចិត្តបំផុតដល់និស្សិត ឪពុកម្តាយ និងរដ្ឋាភិបាលក្នុងការរស់នៅអំឡុងពេលសិក្សា។ វាមិនត្រឹមតែផ្តល់អារម្មណ៍សុវត្ថិភាពថែមទាំងជាកន្លែងដែលនិស្សិតរៀនរស់នៅដោយឯករាជ្យ និងបង្រៀននិស្សិតឱ្យចេះរៀនរស់នៅជាមួយគ្នាកសាងមិត្តភាពជាមួយគ្នា ព្រមទាំងផ្តល់អារម្មណ៍ផ្សារភ្ជាប់រវាងសាលានិងនិស្សិត ជាពិសេសទៀតនោះអន្តេវាសិកដ្ឋាន គឺជួយសន្សំសំចៃថវិកា និងចំណេញពេលវេលាបានយ៉ាងច្រើនដល់និស្សិតសម្រាប់ការស្នាក់នៅ។ កត្តានេះបានផ្តល់បរិយាកាសយ៉ាងអំណោយផលដល់និស្សិតក្នុងការបន្តការសិក្សារហូតដល់ចំណុចគោលដៅ ជាពិសេស ចំពោះនិស្សិតមានសេដ្ឋកិច្ចគ្រួសារមិនសូវធូរជា ឬត្រូវពឹងផ្អែកលើវិស័យកសិកម្ម។ ឆ្លងតាមការសម្ភាសបង្ហាញថា និស្សិតដែលរស់នៅក្នុងអន្តេវាសិកដ្ឋានសាលា គឺមិនតម្រូវឱ្យបង់ថ្លៃចំណាយ ឬតម្រូវបង់ការចំណាយតិចតួចបំផុតត្រឹមតែ ១០០០០ រៀលក្នុងមួយខែប៉ុណ្ណោះសម្រាប់ជួយការថែទាំជួសជុលអគារ និងសម្ភារៈផ្សេងៗ។

បើយើងក្រឡេកមើលតថភាពជាសកលវិញ អន្តេវាសិកដ្ឋានសាលាផ្តល់ឱកាសដល់និស្សិតរបស់ខ្លួននូវសិទ្ធិស្មើគ្នា ដោយមិនប្រកាន់ពូជសាសន៍ វណ្ណៈ ភេទ ពណ៌សម្បុរឡើយ ក្នុងការដាក់ពាក្យស្នើសុំស្នាក់នៅអំឡុងពេលសិក្សា ហើយជាទីកន្លែងដែលពេញនិយមបំផុតសម្រាប់និស្សិតទូទៅមិនថាអ្នកមាន ឬអ្នកក្រឡើយ ហេតុនេះសាលានីមួយៗ តែងតែយកចិត្តទុកដាក់កសាងអន្តេវាសិកដ្ឋានក្នុងបរិវេណសាលា ថែមទាំងអគារមានរចនាដ៏ល្អប្រណិត និងមានសណ្តាប់ធ្នាប់ការរស់នៅល្អ។ តាមការសង្កេតគ្រឹះស្ថានឧត្តមសិក្សាអប់រំនៅកម្ពុជាយើង ជាពិសេសគ្រឹះស្ថានឧត្តមសិក្សាស្ថិតនៅទីក្រុងភ្នំពេញ ភាគច្រើននៅមិនទាន់មានលទ្ធភាពផ្គត់ផ្គង់អគារអន្តេ វេសិកដ្ឋានឱ្យបានគ្រប់គ្រាន់ដល់និស្សិតខ្លួននៅឡើយទេ។

សព្វថ្ងៃនេះ អគារអន្តេវាសិកដ្ឋាននៅទីក្រុងភ្នំពេញមានកន្លែងកំណត់ដោយសារតម្រូវការខ្ពស់ជាងការផ្គត់ផ្គង់ បានធ្វើឱ្យរាជរដ្ឋាភិបាលបានកំណត់លក្ខខណ្ឌមួយចំនួនសម្រាប់ជ្រើសរើសនិស្សិតជាអាទិភាពឱ្យទទួលបានសិទ្ធិស្នាក់នៅស្របច្បាប់ ដូចជា៖ ១) បេក្ខជនពិការ ២) កូនកំព្រា ៣) គ្រួសារមានកូនច្រើន ៤) គ្រួសារក្រីក្រ ៥) បេក្ខជនមកពីខេត្តដាច់ស្រយាល និងតំបន់ជួបការលំបាក។ ចំពោះការចូលរួមវិភាគទានរបស់និស្សិតដើម្បីទ្រទ្រង់មជ្ឈមណ្ឌលអន្តេវាសិកដ្ឋាន និស្សិតម្នាក់តម្រូវជួយឧបត្ថម្ភ ៣០ ដុល្លារក្នុងមួយឆ្នាំ ឬស្មើ ១០០០០ រៀល ក្នុងមួយខែ។ ថវិកានេះដើម្បី៖ ១) ប្រាក់ខែបុគ្គលិកបម្រើការនៅអន្តេវាសិកដ្ឋាន ២) ជួសជុលបន្ទាន់ៗ និងជួសជុលខ្នាតតូច ៣)ការថែទាំបរិស្ថាន និងនិស្សិតមានជម្ងឺធ្ងន់ ៤)ការប្រជុំ។

នៅពេលដែលក្រុមការងារចុះស្រាវជ្រាវទាក់ទងនឹងអន្តេវាសិកដ្ឋាន យើងបានរកឃើញថា បរិស្ថានរស់នៅក្នុងបន្ទប់ និងអគារ គឺនៅមិនទាន់ឆ្លើយតបល្អទៅនឹងការរស់នៅឡើយទេ អគារមានសភាពចាស់ទ្រុឌទ្រោម និងមិនមានផាសុខភាពល្អ ខ្វះគ្រែគេងតាមសាកលវិទ្យាល័យនីមួយៗ ហើយចំនួននិស្សិតចន្លោះចាប់ពី ៦ ទៅ ១០រូបឯណោះក្នុងមួយបន្ទប់ដែលចំនួននេះមិនសមាមាត្រទៅនឹងទំហំបន្ទប់ឡើយ។ ក្នុងពេលសម្ភាស លោកគ្រូទទួលបន្ទុកអគារបាននិយាយចំៗថា "គុណភាពអគារចាស់មិនមានថវិកាជួសជុលអគារឱ្យទាន់ពេលវេលា មានអគារខ្លះបានប្រេះ និងស្រុតដែលបង្កឱ្យមានហានិភ័យដល់សាលា និងនិស្សិត" ហើយមាននិស្សិតនារីខ្លះបានត្អូញត្អែរថា អគារស្នាក់នៅតែងតែជួបបញ្ហាអនាម័យ មិនមានទឹកផ្គត់ផ្គង់គ្រប់គ្រាន់ និងប្រព័ន្ធលូមិនបានល្អធ្វើឱ្យមានក្លិនមិនល្អនៅជុំវិញបរិស្ថានរស់នៅ។

### ៤.៣ ការទទួលរងបន្ទុកគ្រួសារ

ក្នុងចំណោមនិស្សិតចូលរួមឆ្លើយសំណួរ មាននិស្សិតនារីចំនួន ៦៤.៥០% បានឆ្លើយថា ពួកគេអាចរស់នៅដោយខ្លួនឯងបាន តាមរយៈការរកបានការងារធ្វើដោយខ្លួនឯង ការទទួលបានអាហារូបករណ៍សាលា អាហារូបករណ៍ថ្នាក់ដឹកនាំ សប្បុរសជនបរទេស និងតាមសមាគមន៍សាសនាព្រះយេស៊ូគ្រិស្ត។ល។ ក្នុងចំណោមនិស្សិតនារី២៧៦រូប មានចំនួន៨២រូបអាចរកបានការងារធ្វើពេញម៉ោង (៤៦.០០%) និងក្រៅម៉ោង (៥៤.០០%) និងមាន ១៧.៨% អាចធ្វើប្រាក់ជូនគ្រួសារក្នុងអំឡុងពេលសិក្សា។ និស្សិតនារីមួយចំនួនមិនត្រឹមតែអាចធ្វើការងារចិញ្ចឹមជីវិតនិងផ្គត់ផ្គង់ការរៀនសូត្រ ដោយខ្លួនឯងបានប៉ុណ្ណោះទេ តែថែមទាំងអាចមានលទ្ធភាពធ្វើប្រាក់ជូនឪពុកម្ដាយនៅឯស្រុកកំណើតថែមទៀត។ តាមទិន្នន័យបង្ហាញថា មានកត្តា៤យ៉ាងធំៗដែលពួកគាត់ត្រូវធ្វើ៖ ១) ជួយសម្រួលជីវភាពក្នុងគ្រួសារ ២) ជួយដោះបំណុលឪពុកម្ដាយ ៣) ជួយឱ្យប្អូនរៀនសូត្រ ៤) បញ្ហាសុខភាពឪពុកម្ដាយ (តារាងទី៣)។ ប្រាក់ខែដែលនិស្សិតនារីទទួលបានចន្លោះចាប់ពី ៤ ម៉ឺន រហូតដល់ ២ លានរៀល ក្នុងមួយខែ ហើយពួកគាត់ជារឿយៗ

តែងតែផ្ញើជូនឪពុកម្តាយចាប់ពី ២ ម៉ឺនរហូតដល់ ៨០ ម៉ឺនរៀលក្នុងមួយខែ។ ការជួយរំលែកបន្ទុកគ្រួសារនេះក៏ជាការដាក់បន្ទុកឱ្យពួកគាត់មួយកម្រិតទៀត ក្នុងខណៈពេលដែលពួកគាត់ក៏ជួបការខ្វះខាត និងត្រូវការចំណាយជាច្រើនលើការសិក្សា និងជីវភាពរស់នៅខ្លួនឯង។ ក្រោមហេតុផលនេះយើងអាចសន្និដ្ឋានបានថា កាលណាកម្រិតជីវភាពឪពុកម្តាយកាន់តែលំបាក កូនៗនឹងទទួលរងផលប៉ះពាល់ពីសម្ពាធគ្រួសារកាន់តែធ្ងន់ ជាលទ្ធផលចុងក្រោយពួកគាត់អាចឈានរហូតដល់កើតមានបញ្ហាសុខភាព និងបោះបង់ការសិក្សា។

មាននិស្សិតនារីម្នាក់បានឆ្លើយថា "តាមពិតប្រាក់ខែដែលខ្ញុំទទួលបានពីការងារមិនគ្រប់គ្រាន់ទេសម្រាប់ការចំណាយ តែខ្ញុំត្រូវតែផ្ញើពីព្រោះតែគ្រួសារជួបការលំបាកខ្លាំងពេក។ គាត់បានបន្តទៀតថា និស្សិតនារីក្រីក្រភាគច្រើនមានលទ្ធភាពមករៀននៅទីក្រុងភ្នំពេញ មិនមែនក្រោមការជួយឧបត្ថម្ភពីប្រភពឪពុកម្តាយសុទ្ធនោះទេ ផ្ទុយទៅវិញប្រភពមួយភាគធំ គឺបានមកពីមូលនិធិអង្គការ ឬសប្បុរសជនផ្សេងៗ ដោយពួកគាត់ជួយបង់ថ្លៃការសិក្សា និងជួយផ្តល់កន្លែងស្នាក់នៅឱ្យថែមទៀត។ ហើយប្រភពមួយទៀត គឺបានមកពីការទទួលបាន អាហារូបករណ៍រដ្ឋ និងអាហារូបករណ៍សាលាផ្តល់ឱ្យផ្ទាល់តែម្តង។ ទាំងនេះពិតជាជួយសម្រួលដល់ការចំណាយពួកគាត់ តែអ្វីដែលត្រូវចំណាយចំពោះមុខមួយទៀតគឺលើជីវភាពរស់នៅ និងកន្លែងស្នាក់នៅ។"

និស្សិតនារី ៤៨.០៨% បានត្អូញត្អែរលើតម្លៃទំនិញនៅទីក្រុងភ្នំពេញ ហើយពួកគាត់ត្រូវការចំណាយច្រើនជាងនិស្សិតប្រុស ដូច្នេះ ពួកគាត់ត្រូវការចាយវាយដោយសន្សំសំចៃបំផុតសម្រាប់ជីវភាព។ ជាការកត់សម្គាល់មួយទៀត ការសិក្សានេះបានរកឃើញថា និស្សិតនារីទាំងអស់បានឆ្លើយថា ឪពុកម្តាយរបស់គាត់តែងតែជំរុញ និងគាំទ្រនៃការសិក្សាកូនស្រីក្នុងកម្រិតឧត្តមសិក្សា តែដោយសារកត្តាជីវភាពក្រីក្រជារបាំងឧបសគ្គរាំង ធ្វើឱ្យគាត់ពិបាកបន្តការសិក្សា ដូច្នេះការចូលរួមកាត់បន្ថយភាពក្រីក្រ គឺជាការលើកកម្ពស់គុណភាពអប់រំចំពោះសិស្សស្រី និងសមភាពយេនឌ័រក្នុងសង្គម។

ជាការសន្និដ្ឋាន និស្សិតនារីជាពិសេសជានិស្សិតដែលមានជីវភាពគ្រួសារក្រីក្រ ពួកគាត់តែងតែអនុវត្តន៍ការរៀនបណ្តើរ និងធ្វើការបណ្តើរ ហើយរៀនតែមួយសាកលវិទ្យាល័យប៉ុណ្ណោះដោយពួកគាត់ទុកពេលវេលា ដើម្បីស្វែងរកការងារធ្វើពេញម៉ោង ឬក្រៅម៉ោងទៅវិញ។ ហើយពួកគាត់មួយចំនួនបានបែងចែកប្រាក់ខែមួយចំនួនផ្ញើជូនឪពុកម្តាយ ដើម្បីជួយសម្រួលជីវភាពគ្រួសារថែមទៀត។

**តារាងទី៣៖ ទិន្នន័យបង្ហាញពីមូលហេតុដែលនិស្សិតនារីផ្ញើប្រាក់ទៅគ្រួសារក្នុងអំឡុងពេលសិក្សា (n= 276)**

| មូលហេតុដែលនិស្សិតផ្ញើប្រាក់ទៅគ្រួសារ | ភាគរយ(%) |
|---|---|
| ជួយសម្រួលជីវភាពក្នុងគ្រួសារ | 43.5 |

| | |
|---|---|
| ជួយអោយប្អូនរៀន | 22.4 |
| ដោះស្រាយបំណុលគ្រួសារ | 20.0 |
| បញ្ហាសុខភាពក្នុងគ្រួសារ | 14.1 |

## ៤.៤ បញ្ហាសុខភាព

សុខភាពគឺជាទ្រព្យសម្បត្តិដ៏មានតម្លៃដំបូងបំផុតសម្រាប់មនុស្សគ្រប់រូប។ ពេលដែលមានសុខភាពល្អ មនុស្សតែងតែមានសេចក្តីសង្ឃឹមជានិច្ចក្នុងការតស៊ូ និងជម្នះគ្រប់ឧបសគ្គក្នុងជីវិតដើម្បីភាពជោគជ័យ សុខភាព ដូចជា ឫសរុក្ខជាតិ បើឫសមានសុខភាពល្អ នោះរុក្ខជាតិនឹងលូតលាស់ល្អ និងផលិតបានផ្លែផ្កាល្អ។ តែបើក្រឡេកមើលតថភាពជាក់ស្តែងនៅពេលចុះសម្ភាសបានរកឃើញថា និស្សិតនារីមួយភាគធំមានសុខភាពខ្សោយ ឧស្សាហ៍ឈឺ និងឆាប់ហត់ នេះបើផ្អែកតាមការសម្ភាសជាមួយអ្នកគ្រូទទួលបន្ទុកមើលការខុសត្រូវនិស្សិតនារី អ្នកគ្រូបានមានប្រសាសន៍ថា៖

*"ខ្ញុំសង្កេតឃើញថា និស្សិតនារីដែលឪពុកម្តាយមានជីវភាពក្រីក្រមករៀននៅភ្នំពេញឃើញឧស្សាហ៍ឈឺណាស់ តិចៗសន្លប់ តិចៗសន្លប់ ដោយមិនដឹងមូលហេតុច្បាស់លាស់ ហើយបើសង្កេតមើលទៅពួកគាត់ គឺមានសុខភាពខ្សោយ តែសំណាងល្អដែលពួកគេមានប្រាក់ឧបត្ថម្ភសម្រាប់មើលជំងឺ តែប្រាក់ទាំងនេះគឺបានមកពីមូលនិធិសប្បុរសជនទេ។"*

ចំពោះបញ្ហានេះ លោកគ្រូសាកលវិទ្យាធិការមួយរូប ក៏ទទួលស្គាល់ផងដែរចំពោះបញ្ហាសុខភាពនិស្សិតដោយរូបលោក ឃើញថា និស្សិតឧស្សាហ៍កើតខ្យល់ចាប់ ហើយពេលខ្លះត្រូវបញ្ជូនទៅមន្ទីរពេទ្យទាំងយប់ កណ្តាលអធ្រាត្រ តាមការសង្កេតរបស់លោក គឺដោយសាររបបអាហាររបស់និស្សិតមិនគ្រប់តែម្តង ដូច្នេះ រូបលោកតែងតែចេញប្រាក់ហោប៉ៅផ្ទាល់ខ្លួនដើម្បីឱ្យនិស្សិតទៅទិញអាហារបំប៉នបន្ថែមបន្ទាប់ពីចេញពីមន្ទីរពេទ្យ។ លោកគ្រូបានបន្ថែមថា សាលាដែលមានអន្តេវាសិកដ្ឋានគឺពិបាកគ្រប់គ្រងជាងសាលាដែលមិនមាន ពីព្រោះពេលរៀនចប់និស្សិតត្រូវរស់នៅក្នុងសាលា ដូចនេះ សាលាត្រូវមើលថែនិងយកចិត្តទុកដាក់ពួកគាត់ទាំងក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សា។

តាមការសង្កេតឃើញ ទោះបីមានសុខភាពមិនសូវអំណោយផលក្តី តែនិស្សិតនារីជាច្រើនមិនបានទៅរកសេវាពិនិត្យសុខភាពឱ្យបានដិតដល់ទេ ដោយសារ៖ ១) មិនសូវស្គាល់ពីរបៀបរបបមន្ទីរពេទ្យ ឬគ្លីនិក (មិនមានអារម្មណ៍ស្និតស្នាល ឬមានអារម្មណ៍ខ្លាច) ២)ខ្វះថវិកា ៣)ខ្វះអ្នកជួយលើកទឹកចិត្ត និងទំនុកបម្រុង។ល។ ដូចនេះ ពួកគេតែងតែលាក់ទុកក្នុងចិត្ត ដោយមិនបានស្វែងរកសេវាពិនិត្យសុខភាពទេ។

ជាការដោះស្រាយលើសេវាសុខភាពសាធារណៈសម្រាប់និស្សិត មានសាកលវិទ្យាល័យមួយដែលស្ថិតនៅទីរួមខេត្តបានចងសម្ព័ន្ធមេត្រីភាព ដោយចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយមន្ទីរពេទ្យរដ្ឋ ដើម្បីជួយកាត់បន្ថយថវិកានិស្សិតពេលព្យាបាលជំងឺ។ សាកលវិទ្យាល័យបានស្នើសុំឱ្យ មន្ទីរពេទ្យធ្វើការបញ្ចុះតម្លៃសេវាព្យាបាលជំងឺចំពោះនិស្សិតកំពុងសិក្សាត្រង់ចំណុចនេះជាការសបញ្ជាក់នូវសេចក្ដីសប្បុរស និងគំរូល្អនៃសាលា ដែលបានគិតគូរដល់សុខទុក្ខសុខភាពនិស្សិតក្នុងអំឡុងពេលសិក្សា។ ជាទស្សនអ្នកស្រាវជ្រាវ វាជាការល្អបំផុតបើសាកលវិទ្យាល័យមិនអាចមានលទ្ធភាពបង្កើតគ្លីនិក ឬកន្លែងប្រឹក្សាសុខភាពសម្រាប់ខ្លួនឯង សាកលវិទ្យាល័យគួរតែស្វែងរកដៃគូចងសម្ព័ន្ធមេត្រីភាពជាមួយមន្ទីរពេទ្យរដ្ឋនានា ដែលស្ថិតនៅជិតសាលា ឬជាកន្លែងដែលនិស្សិតងាយទៅដល់មកដល់ ដើម្បីជួយសម្រួលការចំណាយដល់និស្សិតជាពិសេសនោះនិស្សិតនារីមានជីវភាពលំបាកក្នុងអំឡុងពេលសិក្សា។

## ៤.៥ កង្វះសេវាផ្ដល់ប្រឹក្សាក្នុងសាលា

នៅក្នុងសាកលវិទ្យាល័យ ផ្នែកផ្ដល់សេវាប្រឹក្សា និងសេវាទ្រទ្រង់សកម្មភាពនិស្សិតជាផ្នែកមួយយ៉ាងសំខាន់ក្នុងការចូលរួមលើកកម្ពស់គុណភាពអប់រំដល់និស្សិតក្នុងសាលា ពីព្រោះនៅពេលដែលនិស្សិតមានបញ្ហាផ្សេងៗ ដូចជា ការសិក្សា ការរស់នៅ ការស្វែងរកការងារ បញ្ហាផ្លូវចិត្ត ពួកគាត់អាចរត់ទៅរកទទួលសេវានេះ ដើម្បីជួយដោះស្រាយជូនពួកគាត់។ ហើយនៅពេលដែលនិស្សិតមានបំណងបង្កើតសកម្មភាពមនុស្សធម៌ ឬសង្គមផ្សេងៗ សាលាត្រូវមានសេវាជួយគាំទ្រ ដើម្បីជួយសម្រួលដល់សកម្មភាពពួកគាត់ ហើយបំផុសបំផុលពួកគាត់ចូលរួមសកម្មភាពសង្គមឱ្យបានសកម្ម និងច្រើនសម្បូរបែបទាំងក្នុងនិងក្រៅសាលា។ តាមទិន្នន័យបង្ហាញថា នៅពេលនិស្សិតនារីជួបបញ្ហា ឬមានបញ្ហាម្ដងៗ និស្សិតដែលទៅរកប្រឹក្សាយោបល់ជាមួយសាលា (គ្រូបង្រៀន) មានចំនួន ១៩.៧០% ចំណែកប្រឹក្សាជាមួយមិត្តភក្ដិមានចំនួន ៣០.៩០% ព្រមទាំងជាមួយក្រុមគ្រួសារ និងសាច់ញាតិមានចំនួន ៤៧.១០% នេះជាការឆ្លុះបញ្ចាំងឱ្យឃើញថាភាពពេញនិយមនៃនិស្សិតនារីទៅស្វែងរកសេវាប្រឹក្សាយោបល់ជាមួយក្រុមគ្រួសារ និងសាច់ញាតិ និងមិត្តភក្ដិ គឺមានច្រើនជាងការស្វែងរកប្រឹក្សាជាមួយសាលា **(តារាងទី៤)**។ ហើយមាននិស្សិតនារីប្រមាណ១៤%ក៏សម្ដែងការមិនពេញចិត្តចំពោះការមិនយកចិត្តទុកដាក់ពីសាលា និងសង្គម និងក៏មាននិស្សិតប្រមាណ ១២% សម្ដែងការមិនពេញចិត្តចំពោះគុណភាពអប់រំសាលាមិនបានល្អដូចអ្វីដែលបានរំពឹងទុកពីមុនមកផងដែរ។ ក្រៅពីនេះទិន្នន័យក៏បង្ហាញថា បច្ចុប្បន្នភាពមាននិស្សិតនារីចំនួន ៣៨.០២% បានឆ្លើយតបថា ពួកគាត់មិនមានអ្នកប្រឹក្សាជាមួយ និងមាន៥២.០១% ខ្វះការលើកទឹកចិត្ត និងទំនុកបម្រុង ព្រមទាំងមួយចំនួនទៀតបានឆ្លើយថា ពួកគាត់គ្មានអ្នករាប់អាន ៩.៧០% **(តារាងទី៥)**។ លើសពីនេះទៀតក្នុងចំណោមនិស្សិតនារីចូលរួមសម្ភាស មាននិស្សិត១១.០៤%

មានគំនិតឈានទៅរកការបោះបង់ការសិក្សាចោលក្នុងអំឡុងពេលសិក្សា ដោយក្រោមមូលហេតុភាពអស់សង្ឃឹមនៃការសិក្សា ជីវភាពគ្រួសារ ការលំបាកក្នុងការរស់នៅ និងកត្តាការងារក្រៅម៉ោងធ្វើឱ្យរំខានដល់ការសិក្សា។ ហើយនៅពេលចុះសម្ភាសជាមួយលោកគ្រូអ្នកគ្រូទទួលបន្ទុកនិស្សិត លោកទាំងអស់សុទ្ធតែទទួលស្គាល់ថា និស្សិតដែលប្រឈមការបោះបង់ការសិក្សាខ្លាំងជាងគេ គឺជានិស្សិតរៀនឆ្នាំទី១។ ដូច្នេះបើសិនសាលាអាចបង្កើតការិយាល័យ ឬភ្នាក់ងារផ្តល់សេវាប្រឹក្សា និងពិគ្រោះយោបល់ នោះសាលានឹងអាចជួយបណ្តុះនៅស្មារតីតស៊ូ និងការលើកទឹកចិត្តនិងទំនុកបម្រុងបានមួយផ្នែកធំជាមិនខាន ព្រោះវាជាយន្តការមួយដែលអាចធានាបាននៅការថែរក្សានិស្សិតឱ្យរៀនសូត្របានដល់គោលដៅ។

**តារាងទី៤៖ទិន្នន័យបង្ហាញពីការស្វែងរកប្រឹក្សាពេលជួបបញ្ហាក្នុងអំឡុងពេលសិក្សានៃនិស្សិតនារី(n=276)**

| ដំណោះស្រាយពេលជួបបញ្ហា | ភាគរយ(%) |
|---|---|
| ប្រឹក្សាជាមួយគ្រូបង្រៀន | 19.70 |
| ប្រឹក្សាជាមួយមិត្តភក្តិ | 30.90 |
| ប្រឹក្សាជាមួយក្រុមគ្រួសារ និងសាច់ញាតិ | 47.10 |
| ប្រឹក្សាតាមបណ្តាញសង្គមដូចជា ហ្វេសប៊ុក ជាដើម | 1.90 |
| ប្រឹក្សាជាមួយចៅកែ | 0.40 |

**តារាងទី៥៖ ទិន្នន័យបង្ហាញពីសម្ពាធផ្សេងៗដែលនិស្សិតនារីបានជួបបញ្ហាក្នុងអំឡុងពេលសិក្សា (n = 276)**

| សម្ពាធផ្សេងៗ | ភាគរយ (%) |
|---|---|
| គ្មានអ្នករាប់អាន | 9.70 |
| ខ្វះការលើកទឹកចិត្ត និងទំនុកបម្រុង | 52.10 |
| អត់មានអ្នកប្រឹក្សា | 38.20 |

## ៤.៦ ឱកាសនិស្សិតនារីក្នុងកំឡុងពេលថ្នាក់ឧត្តមសិក្សា

ជាការពិតណាស់ រាល់បញ្ហាប្រឈមទាំងអស់ សុទ្ធតែបង្កប់ឱកាសនៅក្នុងនោះបើសិនជាយើងអាចតស៊ូជម្នះបាន បញ្ហាប្រឈមទាំងនោះនឹងប្រែក្លាយជាឱកាសមិនខាន។ ក្នុងនោះដែរ តាមរយៈការចុះសម្ភាសបង្ហាញថា និស្សិតនារីក៏បានចាប់យកឱកាសជាច្រើនផងដែរក្នុងអំឡុងពេលសិក្សាដូចបញ្ជាក់ខាងក្រោម៖

### ៤.៦.១ ឱកាសទទួលបានចំណេះដឹង

ការពង្រឹងខ្លួនតាមរយៈការអប់រំ គឺជាមាគ៌ាមួយដ៏ត្រឹមត្រូវបំផុតសម្រាប់ជីវិត តែការទទួលបានចំណេះដឹងវាមិនមែនជាការស្រួលដែលមនុស្សគ្រប់រូបអាចធ្វើបាននោះទេ ពីព្រោះការអប់រំត្រូវការទេពកោសល្យ និងភាពអំណត់តស៊ូ លះបង់ពេលវេលា និងថវិកា រហូតពេលខ្លះត្រូវការរស់នៅចាកឆ្ងាយពីក្រុមគ្រួសារប្ដីប្រពន្ធកូនថែមទៀត ដើម្បីទទួលបានចំណេះដឹងមកបម្រើជាតិ។ តាមទិន្នន័យបង្ហាញថានិស្សិតនារីមានរហូតដល់ ៩០.៤០% សម្រេចចិត្តតស៊ូរៀនសូត្ររហូតបញ្ចប់ការសិក្សាជាស្ថាពរ ទោះបីពួកគាត់ស្ថិតក្នុងស្ថានភាពលំបាកយ៉ាងណាក៏ដោយ។ ពួកគាត់នៅតែឱ្យតម្លៃ និងមានជំនឿលើការអប់រំព្រោះ ១ (ការអប់រំនឹងធ្វើឱ្យខ្ញុំក្លាយជាមនុស្សមានតម្លៃសម្រាប់អភិវឌ្ឍន៍សង្គមជាតិ ២ (ការអបរំនឹងជួយពង្រឹងសមត្ថភាពក្នុងការអភិវឌ្ឍប្រទេសជាតិនិងសង្គមកាន់តែល្អ ៣ (ការអបរំនឹងធ្វើឱ្យមានការផ្លាស់ប្ដូរជីវិតខ្ញុំកាន់តែប្រសើរឡើង ៤ (ការអប់រំនឹងកែប្រែជីវភាពក្រុមគ្រួសារខ្ញុំ ៥ (ការអប់រំនឹងអាចឱ្យខ្ញុំរកការងារធ្វើបានល្អប្រសើរ និងទទួលបានប្រាក់ខែច្រើន ៦ (ក្រុមគ្រួសារខ្ញុំស្រឡាញ់អ្នកមានចំណេះដឹង។

ដូចជាអ្វីដែលបានដកស្រង់ចេញសម្ដីពិតពីនិស្សិតនារីឆ្នាំទី៤ ម្នាក់ដែលមានជីវភាពគ្រួសារក្រលំបាក និងជាក្មេងកំព្រាម្ដាយហើយមានឪពុកជាចាស់ជរាថែមទៀត ចំណែកកន្លែងស្នាក់នៅវិញគឺយកទ្រុងមាន់ធ្វើជាផ្ទះបាននិយាយចេញពីចិត្តថា៖

*“មូលហេតុ ដែលខ្ញុំមិនចង់បោះបង់ការសិក្សា ដោយសារខ្ញុំចង់ដឹងចង់ឃើញនូវអ្វីដែលថ្មី ចំណេះដឹងប្លែកៗ ដែលខ្ញុំមិនដែលបានឃើញ។ ហើយខ្ញុំជឿជាក់ថា ចំណេះដឹងអាចកែប្រែវាសនារបស់ខ្ញុំបាន។ ម្យ៉ាងទៀត កាលខ្ញុំនៅតូច ឪពុករបស់ខ្ញុំលោកបាននិយាយថា លោកគ្មានអ្វីចែកឱ្យពួកខ្ញុំជាកេរ្តិ៍ទេ មានតែឱ្យពួកខ្ញុំខំរៀន ទើបជាស្ពានចម្លងពួកខ្ញុំទៅបាន។ ម្យ៉ាងដោយសារតែភាពក្រីក្រទើបធ្វើឱ្យប្អូនប្រុសរបស់ខ្ញុំត្រូវសម្រេចចិត្តឈប់រៀន។ ដូច្នេះ ក្នុងនាមខ្ញុំជាបង ខ្ញុំត្រូវខិតខំរៀនឱ្យចប់ និងស្វែងរកការងារដើម្បីជួយគាត់វិញ។”*

តាមរយៈពាក្យសម្ដីខាងលើនេះ យើងអាចទាញសេចក្ដីសន្និដ្ឋានថា និស្សិតនារីម្នាក់នេះពិតជាមានការប្ដេជ្ញាចិត្តខ្ពស់ចំពោះការស្វែងរកចំណេះដឹង និងសង្ឃឹមថាការអប់រំនឹងនាំឱ្យឆាកជីវិតរបស់គាត់ផ្លាស់ប្ដូរជាមិនខាន។ ជារួមការពង្រឹងសមត្ថភាពតាមរយៈការអប់រំ នឹងបង្កើតឱកាសជាច្រើនសម្រាប់សង្គមជាតិ និងខ្លួនឯង បើពួកគាត់អាចតស៊ូរៀនបានជោគជ័យជាស្ថាពរក្នុងវិថីអាជីពជានិស្សិត នោះពួកគេនឹងក្លាយជាធនធានមួយដ៏មានតម្លៃសម្រាប់ការលះបង់ជូនសង្គមជាតិ និងមានជីវិតល្អប្រសើរឡើងជាមិនខាន ព្រោះការអប់រំនឹងអាចនាំឱ្យមនុស្សគ្រប់រូបចាកឆ្ងាយផុតពីជីវិតក្រលំបាក។ ហេតុនេះ

យើងត្រូវជំរុញនិងគាំទ្រការសិក្សារបស់និស្សិតនារីឱ្យផុសផុល ដើម្បីឱ្យពួកគេមានឱកាសសិក្សារហូតក្លាយខ្លួនជាធនធានមួយដែលសង្គម និងពិភពលោកត្រូវការក្នុងការចូលរួមចំណែកដឹកនាំ ការពារ និងអភិវឌ្ឍទាំងអស់គ្នា។

### ៤.៦.២ ឱកាសទទួលបានការយកចិត្តទុកដាក់ពីសាលា

តាមទិន្នន័យខាងលើពិតជាសបញ្ជាក់ឱ្យឃើញថា និស្សិតនារីភាគច្រើនមានឱកាសទទួលបានការងារធ្វើក្នុងទម្រង់ "រៀនបណ្ដើរ ធ្វើការបណ្ដើរ" និស្សិតមិនត្រឹមតែអាចរស់នៅដោយខ្លួនឯងបានថែមទាំងរហូតអាចឈានដល់ការផ្ញើប្រាក់ជូនក្រុមគ្រួសារផងដែរ (**តារាងទី៣**)។ សាលាបានផ្ដល់ឱកាសការងារដល់និស្សិត និងថែមទាំងជួយស្វែងរកការងារធ្វើដល់និស្សិតថែមទៀត ដូចពេលដែលចុះសម្ភាស លោកគ្រូម្នាក់បានមានប្រសាសន៍ថា *"នៅពេលដែលសាលាសង្កេតឃើញនិស្សិតមានជីវភាពលំបាកខ្លាំង សាលាតែងតែយកចិត្តទុកដាក់ដល់និស្សិតដោយផ្ដល់ការងារឱ្យនិស្សិតធ្វើនិងផ្ដល់ប្រាក់ខែ ៥០ដុល្លារក្នុងមួយខែ ដើម្បីសម្រួលជីវភាពដល់ពួកគាត់។ ហើយសាលាក៏បើកឱកាសទូលាយសម្រាប់ពួកគាត់ក្នុងការស្វែងរកការងារខាងក្រៅដោយខ្លួនឯងបន្ថែមទៀត"*។ **តារាងទី៦** បង្ហាញពីអត្ថប្រយោជន៍នានាដែលសាកលវិទ្យាល័យមួយចំនួនបានផ្ដល់ដល់និស្សិតកម្មសិក្សាការីទាំងពេញម៉ោង និងក្រៅម៉ោងក្នុងអំឡុងពេលសិក្សា។ យើងសង្កេតឃើញថា ការងាររដ្ឋបាលជាការងារដែលពេញនិយមជាងគេក្នុងចំណោមប្រភេទការងារសាកលវិទ្យាល័យផ្ដល់ជូនដល់និស្សិតហាត់ការ ហើយប្រាក់ខែដែលទទួលបានជាមធ្យមប្រហែល២០ម៉ឺនរៀលក្នុងមួយខែ។

ក្រៅពីនេះទៀត សាលាក៏ផ្ដល់ឱកាសនានាដល់និស្សិតនារីក្នុងការទទួលបានអាហារូបករណ៍ពីមជ្ឈដ្ឋាននានា ដូចជា អាហារូបករណ៍ក្រសួង អាហារូបករណ៍សាលា អាហារូបករណ៍ថ្នាក់ដឹកនាំ អាហារូបករណ៍សប្បុរសជន និងមានប្រាក់ឧបត្ថម្ភប្រចាំខែផ្សេងៗទៀត។ ទោះបីយ៉ាងណា អាហារូបករណ៍មួយមុខមិនអាចទប់ស្កាត់ការប្រឈមនៃការបោះបង់ការសិក្សារបស់និស្សិតឡើយ នេះបើតាមការសម្ភាសជាមួយសាកលវិទ្យាធិការមួយរូបដោយលោកបានសម្ដែងថា *"សាកលវិទ្យាល័យរបស់ខ្ញុំក៏នៅតែមានបញ្ហាប្រឈមខ្លាំងចំពោះការបោះបង់ការសិក្សារបស់និស្សិត ទោះបីជា ពួកគាត់ទទួលបានអាហារូបករណ៍ក៏ដោយ តាមដែលខ្ញុំសង្កេតដោយសារប្រាក់ អាហារូបករណ៍និស្សិតបច្ចុប្បន្ននៅមិនទាន់ឆ្លើយតបសម្រាប់ការចំណាយការសិក្សា និងរស់នៅបាននៅឡើយទេ ដូច្នេះនិស្សិតណាដែលមានជីវភាពខ្វះខាត ពួកគាត់ត្រូវបោះបង់ការសិក្សា ដើម្បីស្វែងរកការងារនៅក្នុងទីក្រុងវិញ។ លោកសាកលវិទ្យាធិការបានបន្តទៀតថា ដើម្បីទប់ស្កាត់បញ្ហានេះ រាជរដ្ឋាភិបាលគួរតម្លើងប្រាក់អាហារូបករណ៍ធ្វើយ៉ាងណាឱ្យពួកគាត់ចាយគ្រប់សម្រាប់ខ្លួនឯងដោយចាប់ពី ៥០ ទៅ ៧០ដុល្លារក្នុងមួយខែ។"*

អ្នកស្រាវជ្រាវសង្កេតឃើញថា ចំពោះសាកលវិទ្យាល័យរដ្ឋ ជាពិសេសសាលាដែលស្ថិតនៅតាមបណ្ដាខេត្តបានផ្ដល់កន្លែងស្នាក់នៅ (អគារអន្តេវាសិកដ្ឋាន) ដល់និស្សិតដោយឥតគិតថ្លៃ ឬបង់ថ្លៃតិចតួចប៉ុណ្ណោះ (តារាងទី៧)។

**តារាងទី៦៖បង្ហាញពីអត្ថប្រយោជន៍នានាដែលសាកលវិទ្យាល័យមួយចំនួនបានផ្ដល់ដល់និស្សិតកម្មសិក្សាការី**

| | ប្រាក់ខែដែលផ្ដល់ក្នុងសាកលវិទ្យាល័យ (ម៉ឺនរៀល) | | |
|---|---|---|---|
| **សាកលវិទ្យាល័យ** | **និស្សិតកម្មសិក្សាការី** | | **តួនាទី** |
| | ក្រៅម៉ោង | ពេញម៉ោង | |
| សា. បាត់ដំបង | ១២ | | ការងារតាមការិយាល័យ |
| សា. ក្រចេះ | ១២ | | ការងារតាមការិយាល័យ |
| សា. មានជ័យ | ១៥ - ២០ | ៣២ | ការងារតាមការិយាល័យ |
| សា. ស្វាយរៀង | ២០ - ២៤ | | ការងាររដ្ឋបាល |
| សា. ភូមិន្ទភ្នំពេញ | ២០ | ១២០ | - ពេញម៉ោង៖ ការងាររដ្ឋបាល; ការងារផ្ដល់សេវានិស្សិត; ការងារសហគមន៍<br>-ក្រៅម៉ោង៖ បណ្ណារក្ស; បុគ្គលិកអនាម័យ<br>- សេវាផ្សេងៗ (៤ម៉ឺនរៀលក្នុងមួយថ្ងៃ) ដូចជាកម្មវិធីពិព័រណ៍ ព្រឹត្តិការណ៍ផ្សេង។<br>- សេវាលក់ពាក្យនិងទទួលពាក្យ<br>- ហ្វឹកហាត់របាំ (១ម៉ឺនរៀលក្នុងមួយថ្ងៃ)<br>- ការងារសង្គម (៤ម៉ឺនរៀលក្នុងមួយថ្ងៃ) |
| សា. ជាតិគ្រប់គ្រង | ៤០ - ៦០ | | |

**តារាងទី៧៖ ទិន្នន័យបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់ដល់និស្សិតស្រីក្នុងអំឡុងពេលសិក្សារបស់សាលា** (n = 276)

| **សាលាមានបានយកចិត្តទុកដាក់ខ្ពស់ដល់និស្សិតស្រី** | **ភាគរយ (%)** |
|---|---|
| ផ្ដល់កន្លែងរស់នៅប្រកបដោយសុវត្ថិភាព | 24.50 |
| ផ្ដល់អាហារូបករណ៍ | 37.20 |
| ព្យាបាលជំងឺដោយមិនគិតថ្លៃ | 3.90 |
| ជួយស្វែងរកការងារឱ្យ | 11.30 |

## ៤.៧ ករណីសិក្សាអំពីដំណើរជីវិតសិក្សានិស្សិតនារីក្នុងកម្រិតថ្នាក់ឧត្ដមសិក្សា

សិទ្ធិក្នុងការទទួលបានការអប់រំគឺជាមូលដ្ឋានគ្រឹះដែលមនុស្សគ្រប់រូបត្រូវទទួលបាន ប៉ុន្តែដំណើរជីវិតក្នុងការឆ្ពោះទៅរកការទទួលបានការអប់រំនៃមនុស្សម្នាក់ៗ គឺមិនដូចគ្នានោះទេ វាអាស្រ័យទៅតាមលក្ខខណ្ឌភូមិសាស្ត្រ ស្ថានភាពគ្រួសារ និងការចូលរួមជួយជ្រោមជ្រែងពីរដ្ឋាភិបាល និងសប្បុរសជននានា។ តាមរយៈការសិក្សានេះ អ្នកស្រាវជ្រាវបានសិក្សាចងក្រងជីវប្រវត្តិនិស្សិតនារីចំនួន៤រូបដើម្បីស្វែងយល់អំពីដំណើរជីវិតពិតរបស់ពួកគាត់ក្នុងការស្វែងរកចំណេះដឹង។ ម្យ៉ាងវិញទៀត ដើម្បីរក្សាឯកជនភាពរបស់អ្នកចូលរួមផ្ដល់បទសម្ភាសន៍ អ្នកស្រាវជ្រាវ សម្រេចប្រតិដ្ឋឈ្មោះអ្នកទាំងនោះ ដែលមានដំណើរជីវិតពិតដូចខាងក្រោម៖

- **និស្សិត កញ្ញា**

ជាកូនទី ៥ ក្នុងចំណោមកូន ៦ នាក់ក្នុងគ្រួសារ កញ្ញាគឺជាកូនដែលរៀនបានខ្ពស់ជាងគេ។ កម្រិតជីវភាពលំបាកធ្វើឱ្យបងៗរបស់គាត់ត្រូវបង្ខំចិត្តបោះបង់ការសិក្សា ភាពក្រីក្រពិតជាអាវុធលាក់មុខដែលសម្លាប់ដំណើរជីវិតសិក្សារបស់បងប្អូនគាត់តាំងពីនៅកុមារភាព។ បច្ចុប្បន្ននេះ កញ្ញាកំពុងសិក្សាថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរឆ្នាំទី១ នៅសាលាពុទ្ធិកសិក្សាក្នុងវត្តអារញ្ញ ខេត្តកំពង់ឆ្នាំង បន្ទាប់ពីបានប្រឡងជាប់សញ្ញាបត្រទុតិយភូមិក្នុងឆ្នាំសិក្សា២០១៩។ អ្នកភូមិទទួលស្គាល់ថា គាត់គឺជាក្មេងម្នាក់គត់ដែលបានប្រឡងជាប់ថ្នាក់ទី ១២ ប្រចាំភូមិ។ ការសិក្សាពិតជាធ្វើឱ្យកញ្ញាមិនអាចទទួលបានភាពកក់ក្ដៅពីឪពុកម្ដាយដូចបងប្អូនដទៃទៀតឡើយ។ គាត់ចាប់ផ្ដើមរស់បែកពីក្រុមគ្រួសារចាប់តាំងពីគាត់រៀនថ្នាក់ទី ១ មកម្លេះ។ រស់នៅជាមួយគេបណ្ដើរ រៀនបណ្ដើរតាំងពីកុមារភាពពិតជាមិនងាយស្រួលដូចកូនរស់នៅជួបជុំគ្រួសារឡើយ ហើយទំរាំរៀនចប់ថ្នាក់ទី ១២ កញ្ញាបានធ្វើការផ្លាស់ប្ដូរទីកន្លែងរស់នៅពីមួយទៅមួយ។ ការសិក្សាគឺជាតំណើរជីវិតដ៏វែងឆ្ងាយ មិនចេះចប់មិនចេះហើយ ឆ្លងពីមួយដំណាក់ទៅមួយដំណាក់ទៀត ពីឧបសគ្គមួយទៅឧបសគ្គមួយទៀត ដូចតាមប្រសាសន៍សម្ដេចហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាថា *"គ្មានទេ ទីបញ្ចប់នៃការសិក្សា"*។ បន្ទាប់ពីឆ្លងផុតថ្នាក់ទី ១២ បញ្ហាប្រឈមជាច្រើនទៀតបានមកដល់ដូចជាត្រូវប្រឈមនឹងកង្វះថវិកា ដើម្បីរៀនបន្តទៀតនៅកម្រិតឧត្ដមសិក្សា តែជាភ័ព្វសំណាងគាត់បានទទួលអាហារូបករណ៍រហូតដល់ទៅពីរកន្លែង៖១)អាហារូបករណ៍សិស្សក្រីក្រសិក្សានៅភ្នំពេញ២) អាហារូបករណ៍ពីសាលាពុទ្ធិកសិក្សាក្នុងខេត្តកំពង់ឆ្នាំង។ សម្រាប់ឪពុកម្ដាយដែលមានលទ្ធភាព វាជារឿងមួយដ៏ត្រេកអរក្រៃលែងដែលកូនបានជាប់អាហារូបករណ៍ទៅ

សិក្សានៅទីក្រុងភ្នំពេញ ប៉ុន្តែសម្រាប់ឪពុកម្តាយគាត់វិញ គឺជារឿងមួយដែលពិបាកចិត្តបំផុត ដោយសារតែគ្រួសារមិនមានលទ្ធភាពបញ្ជូនកូនទៅសិក្សានៅទីក្រុងបាន ដូចនេះ ការសម្រេចចិត្តមួយដ៏ត្រឹមត្រូវ និងសប្បាយចិត្តបំផុតសម្រាប់ពួកគាត់ ហើយស្របតាមលក្ខខណ្ឌជីវភាពគ្រួសារផង គឺការជំរុញឱ្យកូនស្រីគាត់ទទួលយកអាហារូបករណ៍ជម្រើសទីពីរ ដោយបញ្ជូនកូនស្រីទៅសិក្សានៅសាលាពុទ្ធិកសិក្សាក្នុងខេត្តកំពង់ឆ្នាំង។ ហើយដោយសារខ្វះថវិកាបង់ប្រាក់ថ្លៃជួលផ្ទះ ឪពុកកញ្ញាសម្រេចចិត្តសុំទីវត្តអារាមសម្រាប់ឱ្យកូនស្នាក់នៅក្នុងអំឡុងពេលសិក្សា។ បច្ចុប្បន្ននេះ កញ្ញាកំពុងរស់នៅក្នុងវត្តជាមួយដូនជី ហើយមិនបានចំណាយលើម្ហូបអាហារ និងកន្លែងស្នាក់នៅឡើយ។ ប្រាក់ឧបត្ថម្ភដែលនាងទទួលបានពីឪពុកម្តាយចន្លោះពី ១៥០០០ ទៅ ២០០០០ រៀលប៉ុណ្ណោះក្នុងមួយសប្តាហ៍សម្រាប់ការចាយវាយប្រចាំថ្ងៃ ការធ្វើដំណើរ និងការរៀនសូត្រ។

ឪពុករបស់កញ្ញាមានតួនាទីជាប្រធានភូមិផង និងកសិករផង ឯម្តាយវិញមានមុខរបរជាកសិករ រស់នៅដោយពឹងផ្អែកលើការធ្វើកន្ទេលកក់និងការដាំបន្លែបង្ការ។ ហាក់បីដូចជាការមើលឃើញកំហុសដែលកូនៗមិនបានរៀនខ្ពស់ និងយល់អំពីតម្លៃនៃការសិក្សា ឪពុកម្តាយនិងបងប្អូនកញ្ញាតែងតែលើកទឹកចិត្ត និងជ្រោមជ្រែងកញ្ញាឱ្យប្រឹងប្រែងរៀនសូត្រកុំបោះបង់ការសិក្សាឱ្យសោះទោះបីប្រឡងមិនជាប់ថ្នាក់ទី១២ ក៏ដោយ ដូចពួកគាត់មានប្រសាសន៍ថា "បងៗបានឈប់រៀនអស់ហើយដោយសារឪពុកម្តាយមិនមានលទ្ធភាព ហើយទុកឱ្យពួកគាត់ជួយធ្វើការរកប្រាក់ជួយគ្រួសារ"។ ភាពអំណត់តស៊ូ និងការប្តេជ្ញាចិត្តក្នុងការសិក្សារបស់កញ្ញា ពិតជាមិនធ្វើឱ្យឪពុកម្តាយអស់សង្ឃឹមឡើយ គាត់បានប្រឹងតស៊ូជម្នះគ្រប់ឧបសគ្គហើយលទ្ធផលចុងក្រោយគាត់បានប្រឡងជាប់ថ្នាក់ទី១២និងពាំនាំភាពជោគជ័យនិងមោទនភាពជូនគ្រួសារទាំងមូល។ ចំពោះសុខភាពនិងកាយសម្បទាលូតលាស់របស់កញ្ញាត្រូវបានឪពុកម្តាយមើលឃើញថា ជាក្មេងស្រីដែលមានសុខភាពមិនរឹងមាំល្អ មាឌតូចល្អិត និងរាងកាយលូតលាស់មិនសូវប្រក្រតី។ តែទោះបីជួបស្ថានភាពលំបាកបែបណាក្តី ក៏ឪពុកម្តាយកញ្ញានឹងតស៊ូឱ្យកូនរៀនរហូតដល់ចប់ជាស្ថាពរ ប៉ុន្តែពួកគាត់ក៏សម្តែងក្តីបារម្ភថា ពួកគាត់ខ្លាចពេលដែលកូនរៀនចេះដឹងទៅ បែរជាមិនបានគិតដល់ម៉ែឪ។ ចំពោះក្តីរំពឹងទុករបស់ឪពុកម្តាយគាត់វិញ បន្ទាប់ពីកូនរៀនចប់ ពួកគាត់ទាំងពីរសង្ឃឹមថា កូនមានការងារធ្វើជាគ្រូបង្រៀននិងមានប្រាក់ខែមួយអាចដោះទាល់ឪពុកម្តាយ និងអាចទុកសម្រាប់ខ្លួនឯងខ្លះ ព្រមទាំងជួយប្អូនៗឱ្យរៀនចេះដឹងដូចខ្លួនឯងដែរ។

ជាចុងបញ្ចប់កញ្ញាបានសំណូមពរថា គាត់ចង់បានកង់មួយសម្រាប់ធ្វើដំណើរ និងបើមានលទ្ធភាព កញ្ញាចង់រស់នៅខាងក្រៅវត្តវិញ ព្រោះគាត់ចង់ស្វែងរកការងារធ្វើ ដើម្បីជួយសម្រួលជីវភាពគ្រួសាររបស់

គាត់ ជាពិសេសប្អូនស្រីគាត់ម្នាក់ទៀតឱ្យមានលទ្ធភាពរៀនបានខ្ពង់ខ្ពស់ដែរ។ កញ្ញាក៏មានក្តីស្រម៉ៃដូចនិស្សិតនារីដទៃទៀតដែរ គឺគាត់ចង់ក្លាយជាគ្រូបង្រៀនម្នាក់នាថ្ងៃអនាគត។

➢ **និស្សិត សាន់លី**

អាហារូបករណ៍ គឺជារឿងសំខាន់ណាស់សម្រាប់និស្សិត សាន់លី ព្រោះបើគ្មានវាទេ សាន់លី ប្រហែលជាមិនអាចបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សាបានឡើយ នេះបើតាមប្រសាសន៍ឪពុកគាត់ថា *"បើគ្មានអាហារូបករណ៍នេះទេ កូនរបស់គាត់ប្រហែលជាមិនអាចបន្តការសិក្សាទៅឧត្តមសិក្សាបានទេ។"* បច្ចុប្បន្ននេះ សាន់លី ជានិស្សិតឆ្នាំទី៤ មហាវិទ្យាល័យកសិកម្ម ជំនាញក្សេតសាស្ត្រ នៃសាកលវិទ្យាល័យមានជ័យ ខេត្តបន្ទាយមានជ័យ។ ទោះបីជាក្មេងដែលកំព្រាម្តាយ និងមានឪពុកចាស់ជរាក្តីក៏ដោយសាន់លី មិនដែលចុះចាញ់នឹងព្រហ្មលិខិតបណ្តោយតាមខ្សែជីវិតរបស់គាត់ឡើយ ផ្ទុយទៅវិញគាត់បានខំប្រឹងប្រែងតស៊ូជម្នះគ្រប់ឧបសគ្គហែលឆ្លងភាពអវិជ្ជារហូតសម្រេចបានដល់កម្រិតថ្នាក់ឧត្តមសិក្សា ថែមទាំងទទួលបានការកោតសរសើរចេញពីសាលាទៀតផង ដូចគាត់និយាយថា "ខ្ញុំធ្លាប់ទទួលបានលិខិតសរសើរពីសាកលវិទ្យាល័យមានជ័យនៅឆ្នាំទី២ ដោយខ្ញុំទទួលបានចំណាត់លេខ២ប្រចាំថ្នាក់ ហើយក៏ធ្លាប់ទទួលបានរង្វាន់លើកទឹកចិត្តពីគ្រូប្រចាំថ្នាក់កាលពីខ្ញុំរៀននៅវិទ្យាល័យផងដែរ ដោយសារខ្ញុំមានសេចក្តីក្លាហានក្នុងការឆ្លើយសំណួរនៅក្នុងថ្នាក់ និងការខិតខំព្យាយាមរៀនសូត្រ។" ទោះជាស្ថានភាពជីវភាពសេដ្ឋកិច្ចគ្រួសារជួបការលំបាក និងមិនសូវអំណោយផលដល់ការសិក្សាកូនក្តី សាន់លីជាក្មេងស្រីម្នាក់ក្នុងចំណោមក្មេងស្រីតិចតួចបំផុតនៅក្នុងភូមិដែលបានសិក្សា ដល់កម្រិតថ្នាក់ឧត្តមសិក្សា នេះបើយោងតាមប្រសាសន៍ឪពុកគាត់ *"ខ្ញុំឃើញថាមានកូនអ្នកភូមិមិនសូវច្រើនប៉ុន្មានទេដែលបានរៀនខ្ពស់ជាងកូនស្រីខ្ញុំ។"*

សាន់លី ជានិស្សិតមិនរស់នៅក្នុងបន្ទុកគ្រួសារ ព្រោះគាត់បានរៀនបណ្តើរ និងធ្វើការបណ្តើរ។ ការងារក្រៅម៉ោងរបស់សាន់លីមានដូចជា៖ ការដាំបន្លែលក់ អ្នករត់តុតាមរោងការ ឬជាគ្រូបង្រៀនសិស្សតាមផ្ទះ និងសាលាឯកជនជាដើម។ ប្រាក់ដែលគាត់រកបានមកពីការងារមានចំនួន១២ម៉ឺនរៀល បូកផ្សំហ្នឹងប្រាក់អាហារូបករណ៍ ៤.៥ ម៉ឺនរៀលក្នុងមួយខែ។ លើសពីនេះទៀត សាន់លី ត្រូវទទួលរងបន្ទុកគ្រួសារជាប់ជាមួយ ហេតុនេះគាត់ត្រូវការចាយវាយដោយសន្សំសំចៃបំផុត ដើម្បីអាចធ្វើប្រាក់ខ្លះជូនគ្រួសារ ហើយការធ្វើនេះ គឺដើម្បីជួយសម្រួលជីវភាពគ្រួសារ ជួយឱ្យប្អូនរៀន ដោះស្រាយបំណុលគ្រួសារ និងបញ្ហាសុខភាពក្នុងគ្រួសារ។ គាត់ក៏បានបង្ហើបអំពីបញ្ហាទុក្ខលំបាកមួយចំនួនផងដែររួមមាន៖ មិនមានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ខ្វះស្បៀងអាហារគ្រប់គ្រាន់សម្រាប់បរិភោគដោយសារពុំមានដីស្រែចម្ការ ខ្វះសម្ភារសិក្សា និងឪពុកចាស់ជរាថែមទៀត។ល។

ជាក្មេងកំព្រាម្ដាយចាប់តាំងពីរៀនថ្នាក់ទី ៤ សាន់លី ជានិស្សិតម្នាក់ក្នុងចំណោមនិស្សិតដទៃទៀតដែលសាលាបានយកចិត្តទុកដាក់ខ្ពស់ ដោយសារសាន់លីជានិស្សិតមានការព្យាយាម និងឧស្សាហ៍ក្នុងការសិក្សា ជាពិសេសគ្រួសារមានជីវភាពក្រីក្រ។ សាលាបានយកចិត្តទុកដាក់ និងបំផុសស្មារតីលើកទឹកចិត្តរបស់និស្សិតខ្លួនគ្រប់វិធីទាំងអស់រួមមានៈ ការផ្ដល់អគារអន្តេវាសិកដ្ឋានស្នាក់នៅដោយឥតគិតថ្លៃ ផ្ដល់ការងារធ្វើក្នុងសាលាក្នុងប្រាក់ខែ ៥០ ដុល្លារក្នុងមួយខែ ជួយស្វែងរកការងារបន្ថែមទៀតឱ្យនិស្សិតធ្វើ (អ្នករត់តុតាមរោងការ ឬកម្មវិធីផ្សេងៗ) ចុះអនុស្សារណៈយោគយល់គ្នាជាមួយមន្ទីរពេទ្យខេត្ត ការបញ្ជូនសិស្សទៅផ្លាស់ប្ដូរយកបទពិសោធន៍ជាមួយសាលាដៃគូក្រៅប្រទេស និងផ្ដល់វគ្គបណ្ដុះបណ្ដាលផ្សេងៗ។ ការជួយជ្រោមជ្រែងរបស់សាលា ពិតជាផ្ដល់តម្លៃខ្ពស់សម្រាប់និស្សិតក្នុងការតស៊ូសិក្សារហូតដល់គោលដៅ។ ចំពោះនិស្សិតដែលជួបការលំបាកបំផុត សាលាបានជួយឧបត្ថម្ភថវិកាដោយការផ្ដួចផ្ដើមរៃអង្គាសប្រាក់នៅក្នុងសាលាបន្ថែមទៀត តែសាលាក៏ទទួលស្គាល់ថា ការជួយរបស់សាលានៅមានកម្រិតនៅឡើយ ដោយសារមាននិស្សិតជួបការលំបាកច្រើនពេក។

បើពិនិត្យមើលស្ថានភាពគ្រួសារគាត់វិញឃើញថា និស្សិតនារីម្នាក់នេះ ជាកូនច្បងក្នុងចំណោមបងប្អូនបីរូបក្នុងគ្រួសារ។ ប្អូនស្រីរបស់គាត់កំពុងរៀនថ្នាក់ទី១១ ក្នុងឆ្នាំសិក្សា២០១៩នេះ ហើយប្អូនប្រុសគាត់ត្រូវបង្ខំចិត្តឈប់រៀនត្រឹមថ្នាក់ទី៧ ដោយសារតែជីវភាពគ្រួសារមិនអំណោយផល។ សព្វថ្ងៃនេះប្អូនប្រុសគាត់ទៅស៊ីឈ្នួលចិញ្ចឹមមាន់ឱ្យគេដោយទទួលបានប្រាក់កម្រៃ ១០០ ដុល្លារក្នុងមួយខែ។ ចំណែកឪពុករបស់គាត់ជាចាស់ជរា មិនអាចប្រកបរបរអ្វីជាដុំកំភួនឡើយ គាត់បានត្រឹមតែរកប្រាក់ចំណូលតាមរយៈការចិញ្ចឹមមាន់ទាជាលក្ខណៈគ្រួសារប៉ុណ្ណោះ ដែលមិនអាចផ្គត់ផ្គង់ជីវភាពគ្រួសារទាំងមូលបានឡើយ។ ដើម្បីរកប្រាក់បន្ថែមជូនគ្រួសារ ប្អូនស្រីរបស់សាន់លី តែងតែទៅជួយលាងចាន និងជួយលក់អីវ៉ាន់បងប្អូនពេលសម្រាកពីការសិក្សា (មួយព្រឹក ឬមួយរសៀល) ដោយទទួលប្រាក់កម្រៃ ៥ពាន់រៀលក្នុងមួយពេល។

ឆ្លងតាមការចុះប្រមូលព័ត៌មានខាងលើ អ្នកស្រាវជ្រាវអាចវាយតម្លៃថា សាន់លីជានិស្សិតម្នាក់ដែលរងបន្ទុកជាច្រើនក្នុងអំឡុងពេលសិក្សា។ គាត់មិនត្រឹមតែទទួលរងបន្ទុកការសិក្សា ថែមទាំងគ្រួសារថែមទៀត។ គាត់ត្រូវចូលរួមដោះស្រាយបន្ទុកទាំងនេះទាំងគាត់នៅមិនទាន់រឹងដៃរឹងជើងខ្លួនឯងនៅឡើយ។ ប្រឹងរៀនបណ្ដើរ ប្រឹងធ្វើការបណ្ដើរ ប្រឹងសន្សំប្រាក់បណ្ដើរ ប្រឹងគិតគូរជីវភាពគ្រួសារបណ្ដើរ ប្រឹងដោះស្រាយបញ្ហាប្រឈមខ្លួនឯងបណ្ដើរ ពិតជាបន្ទុកមួយដល់ធ្ងន់សម្រាប់នារីម្នាក់នេះក្នុងនាមជានិស្សិត។ ទោះបីយ៉ាងណា សាន់លីជានិស្សិតម្នាក់ក្នុងចំណោមនិស្សិតដទៃទៀតដែលសាលាបានយកចិត្តទុកដាក់ និងផ្ដល់ការជ្រោមជ្រែង ហើយសាលាក៏ទទួលស្គាល់ផងដែរពីភាពអំណត់

តស៊ូក្នុងការសិក្សារបស់គាត់។ ជាចុងក្រោយ សាន់លីមានជំនឿថា ចំណេះដឹងនឹងអាចដោះស្រាយ និងលើកកម្ពស់ជីវភាពរស់នៅរបស់គាត់ និងគ្រួសារ។ គាត់មានក្ដីស្រម៉ៃចង់បង្កើតអាជីវកម្មកសិកម្មសរីរាង្គនៅក្នុងសហគមន៍របស់គាត់នាពេលអនាគត។ ហើយគាត់សំណូមពរថា រាជរដ្ឋាភិបាលជួយសម្របសម្រួល គាំទ្រ និងបង្កបរិយាកាសដល់អ្នកវិនិយោគទាំងក្នុង និងក្រៅស្រុកឱ្យបានសុខដុម ដើម្បីបើកទីលំហរទីផ្សារការងារក្នុងស្រុកឱ្យកាន់តែទូលំទូលាយ កត្តានេះនឹងបើកឱកាសដល់និស្សិតដែលបញ្ចប់ការសិក្សាងាយរកការងារធ្វើ។ ជាពិសេស បើអាចទៅរួច រាជរដ្ឋាភិបាលគួរបន្ថែមប្រាក់អាហារូបករណ៍រហូតដល់ចំនួន ១៥ ម៉ឺនរៀលជាប្រចាំខែសម្រាប់ការចំណាយលើម្ហូបអាហារ សម្ភារសិក្សា ការស្នាក់នៅ និងការធ្វើដំណើរដល់សិស្សក្រីក្រ ។

- **និស្សិត វីរ៉ា**

អាហារូបករណ៍ ក៏សំខាន់បំផុតចំពោះនិស្សិតនារីម្នាក់នេះ ពីព្រោះបើគាត់មិនបានទទួលអាហារូបករណ៍ទេ វីរ៉ានឹងមិនអាចបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សាបានឡើយ ដោយគាត់បានពិពណ៌នាដូច្នេះថា "*ពេលប្រឡងជាប់ភ្លាម ក្រុមគ្រួសារខ្ញុំប្រាប់ថា គាត់គ្មានលទ្ធភាពឱ្យខ្ញុំរៀនបន្តទេ ខ្ញុំអង្គុយគិតផង យំផងតែម្នាក់ឯង។ ការទទួលបានអាហារូបករណ៍រៀនមិនយកប្រាក់រយៈពេលបួនឆ្នាំ ដូចមានទឹកសន្សើមមកស្រោចព្រំជីវិតកូនស្រីឱ្យរស់ឡើងវិញ។*" ទោះបី មានកាយសម្បទារមិនអំណោយផល (ពិការជើង)និស្សិត វីរ៉ា បានខិតខំប្រឹង តស៊ូរៀនសូត្ររហូតដល់ថ្នាក់ឧត្តមសិក្សា។ បច្ចុប្បន្ន វីរ៉ា ជានិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ ឆ្នាំទី២ ជំនាញអក្សរសាស្ត្រខ្មែរ នៃមហាវិទ្យាល័យសិល្បៈមនុស្សសាស្ត្រ និងភាសា នៃសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ។ មុននឹងមកដល់ចំណុចនេះ វីរ៉ា ធ្លាប់ជាសិស្សបោះបង់ការសិក្សាចំនួនពីរដងរួចមកហើយ៖ ១) ថ្នាក់បឋមសិក្សាម្ដង (ថ្នាក់ទី៣) ដោយសារសុខភាព (ឈឺ) ២) ថ្នាក់មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៨) ដោយសារអត់មានថវិកា គាត់ត្រូវបង្ខំចិត្តឈប់រៀនដើម្បីទៅធ្វើការនៅរោងចក្រ តែអកុសលគាត់បានជួបគ្រោះថ្នាក់ធ្វើឱ្យពិការភាពចាប់តាំងពីពេលនោះមក។ ប៉ុន្តែក្រោមស្មារតីប្រកាន់ភ្ជាប់នឹងការប្ដេជ្ញាចិត្តខ្ពស់ដែលធ្លាប់សន្យានិងខ្លួនឯងថា "ទោះមានឧបសគ្គយ៉ាងណាក៏មិនឈប់រៀន ព្រោះខ្ញុំស្រឡាញ់ការសិក្សាណាស់" បានធ្វើឱ្យគាត់ត្រឡប់មកសុំចុះឈ្មោះចូលរៀនឡើងវិញ ហើយបានហែលឆ្លងជម្នះគ្រប់ឧបសគ្គជាច្រើនទំរាំឈានជើងចូលថ្នាក់ឧត្តមសិក្សា។ ចំណុចល្អប្រសើររបស់និស្សិតនារីម្នាក់នេះក្នុងការតស៊ូរៀនសូត្រដល់កម្រិតនេះ គឺចេះផ្ដល់កម្លាំងចិត្តឱ្យខ្លួនឯង និងមិនចុះចាញ់នឹងភាពអស់សង្ឃឹម ព្រមទាំងមិនខ្វល់ខ្វាយពាក្យពេជន៍ចេញពីភ្នែកញាតិឬអ្នកដទៃឡើយ ឧទាហរណ៍ គាត់បានពណ៌នាថា "ដោយខ្លួនពិការជើងជិះកង់កាន់ឈើច្រត់ទៅសាលារៀន បានឆ្លងកាត់ភ្នែកអ្នកជិតឆ្ងាយអស់ផងទាំងពួង ហើយអ្នកខ្លះបានសម្ដែងមតិ

ថា ខ្លួនពិការអ៊ីចឹងខំរៀនបានប្រយោជន៍អ្វី អ្នកមានកាយសម្បទាគ្រប់គ្រាន់ រៀនចប់ហើយនៅរកការងារធ្វើមិនបានផង ចុះទម្រាំឯងជាជនពិការ រកការងារអីបានធ្វើ តែខ្ញុំធ្វើមិនដឹងមិនឮ។ ទោះបីមានអារម្មណ៍តូចចិត្តខ្លួនឯងក្ដី ពេលដែលខ្ញុំនឹងឃើញពាក្យសុភាសិតមួយឃ្លាដែលពោលថា "ជីវិតគឺការតស៊ូ" ធ្វើឱ្យនាងខ្ញុំមានកម្លាំងចិត្តឡើងវិញ ហើយហ៊ានកាន់ឈើច្រត់សុំលោកគ្រូចូលរៀន និងប្រឈមមុខជាមួយនឹងសិស្សដទៃទៀត។" ឆ្លងតាមការពិពណ៌នានេះអាចឆ្លុះបញ្ចាំងឱ្យឃើញថា សហគមន៍ដែលស្ថិតនៅជុំវិញគាត់មិនត្រឹមតែមិនចេះលើកទឹកចិត្តគ្នា និងឱ្យតម្លៃការអប់រំ តែបែរជារួមចំណែកជាន់ពន្លិចស្មារតីគ្នាបន្ថែមទៀតក្រោមហេតុផលជាជនពិការមិនមានកាយសម្បទាគ្រប់គ្រាន់ទៅវិញ ឬមួយមកពីការធ្លាក់ចុះភាពជំនឿជឿជាក់ និងទំនុកចិត្តលើវិស័យអប់រំជូនចំពោះជនពិការក្នុងសង្គម។ ជាទស្សនទានរបស់អ្នកស្រាវជ្រាវ ល្គឹកណាសាធារណៈជនអស់ជំនឿជឿជាក់ និងបាត់បង់ទំនុកចិត្តលើវិស័យអប់រំ ល្គឹកនោះប្រទេសជាតិនឹងជួបគ្រោះមហន្តរាយមិនខាន ដូច្នេះការចូលរួមលើកកម្ពស់វិស័យអប់រំទាំងអស់គ្នាដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ កាយសម្បទា ភេទជាដើម គឺជាការលុបបំបាត់ ការកាត់បន្ថយ និងការពារមិនឱ្យមានគ្រោះមហន្តរាយកើតឡើង នាថ្ងៃអនាគត ថែមទាំងជាការផ្ដល់ឱកាសដល់ប្រទេសជាតិមានការរីកចម្រើន សុខដុមបនីយកម្ម និងវិបុលភាព។

អ្វីដែលអ្នកស្រាវជ្រាវចង់រំលេចចំពោះដំណើរជីវិតរបស់និស្សិត វីរ៉ា គឺទឹកចិត្តគ្រូបង្រៀនដែលស្ថិតនៅពីក្រោយភាពតស៊ូរបស់គាត់។ ទោះបីស្ថិតនៅក្នុងកាលៈទេសៈយ៉ាងណាក៏ដោយ គ្រូបង្រៀនតែងនៅកៀកគាត់ជានិច្ច និងផ្ដល់ការលើកទឹកចិត្តប្រកបដោយភាពសុទិដ្ឋិនិយម ព្រមទាំងផ្ដល់កម្មវិធីគាំទ្រដល់សិស្សគ្រប់រូបដោយតម្លៃស្មើភាពគ្នា ដូចគាត់បានលើកឡើងថា "លោកគ្រូអ្នកគ្រូបានលើកទឹកចិត្តខ្ញុំឱ្យខំរៀន នៅថ្ងៃខាងមុខគង់នឹងមានអនាគត ក្រៅពីនេះលោកគ្រូអ្នកគ្រូបានជួយឧបត្ថម្ភថវិកា និងបង្រៀនមិនយកប្រាក់ ផ្ដល់អាហារូបករណ៍ ផ្ដល់ភាពកក់ក្ដៅនិងយកចិត្តទុកដាក់ដល់ខ្ញុំ ព្រមទាំងជួយជ្រោមជ្រែងគ្រប់បែបយ៉ាងធ្វើឱ្យខ្ញុំមានទំនុកចិត្តក្នុងការសិក្សាបន្ថែមទៀត" ជាឧទាហរណ៍ នៅពេលប្រឡងថ្នាក់ទី ១២ លោកគ្រូបានឱ្យថវិកាខ្ញុំទៅប្រឡង ហើយក៏ប្រឡងជាប់ដូចក្ដីប្រាថ្នា ហើយក៏បន្តជួយតាមលទ្ធភាពពេលមករៀននៅសាកលវិទ្យាល័យ។ និស្សិត វីរ៉ា បានធ្វើការលើកសរសើរដោយស្មោះអស់ពីដួងចិត្តនូវទឹកចិត្តលោកគ្រូអ្នកគ្រូដែលតែងតែជួយជ្រោមជ្រែង និងគាំទ្រក្នុងអំឡុងពេលសិក្សារបស់គាត់ ដោយគាត់បានពោលពាក្យថា "លោកគ្រូអ្នកគ្រូនៅទីនេះ មានចិត្តល្អបានជួយខ្សែជីវិតនិស្សិតក្រីក្រនិងឧបត្ថម្ភបន្ថែមទៀត បានជួយផ្ដល់ប្រាក់កាក់ទំនុកបម្រុងក្នុងការរៀនសូត្រ ផ្ដល់សៀវភៅសិក្សា ក្លិបសិក្សាមិនយកលុយ ផ្ដល់អាហារូបករណ៍។ល។ លោកគ្រូអ្នកគ្រូយកចិត្តទុកដាក់គ្រប់ពេលវេលាក្នុងការសិក្សារៀនសូត្ររបស់ខ្ញុំ ហើយខ្ញុំត្រូវពឹងលើគាត់ទាំងស្រុង។" និស្សិត វីរ៉ា ក៏ទទួលបានការ

ជួយជ្រោមជ្រែងខ្លះដែរពីសាសនាយេស៊ូនៅខេត្តព្រៃវែងលើការរៀនសូត្ររបស់គាត់។ ក្រៅពីនេះទៀត កត្តាមួយទៀតដែលគួរឱ្យកត់សម្គាល់នោះ គឺនិស្សិត វីរ៉ា ចេះជួយខ្លួនឯងទាំងការផ្តល់កម្លាំងចិត្ត និងការបង្កើតមុខរបរដោយខ្លួនឯង "ធ្វើផ្កាលក់នៅក្នុងសាលា" ហើយគាត់បានពោលថា "ខ្ញុំធ្លាប់ធ្វើផ្កាលក់តាំងពីវិទ្យាល័យមកម្លេះ ដោយខ្ញុំធ្វើផ្កាលក់នៅពេលយប់ រៀនផង ធ្វើផ្កាផង ធ្វើហើយយកមកលក់នៅសាលារៀន នៅពេលចូលឆ្នាំដើរលក់តាមភូមិ។ ពេលគេទិញច្រើន ខ្ញុំត្រូវធ្វើរហូតដល់ភ្លឺក៏មានដែរ ពុំសូវបានដេកឡើយ ហើយផ្កាដែលគាត់ធ្វើបានលក់ដាច់ផងដែរ។ ពេលត្រឡប់មកពីសាលារៀន ខ្ញុំឆ្លៀតដើររើសអេតចាយតាមផ្លូវរហូតដល់ផ្ទះ។ វាបានជួយសម្អាតបរិស្ថានផង និងយកមកលក់បានប្រាក់កម្រៃផ្គត់ផ្គង់ក្នុងការរៀនសូត្រផង។"

ជាក្មេងកំព្រាឪពុក ថែមទាំងសមាជិកបីរូបក្នុងចំណោមបួនរូបក្នុងគ្រួសារជាជនពិការ និស្សិត វីរ៉ា ពិតជាទទួលរងសម្ពាធទាំងផ្លូវកាយ និងផ្លូវចិត្តជាច្រើនអនេក។ ម្តាយ វីរ៉ា ជាចាស់ជរាមានអាយុ ៧៦ឆ្នាំ ភ្នែកមើលមិនសូវឃើញ ហើយសុខភាពក៏មិនសូវល្អដែរ ចំណែកបងស្រីគាត់ម្នាក់ទៀតមានជំងឺសសៃប្រាសាទមើលមិនជាឡើយ ឯបងស្រីគាត់ម្នាក់ទៀតទោះបីមានកាយសម្បទាគ្រប់គ្រាន់ក្តី តែគាត់ត្រូវទទួលរងបន្ទុកដោះស្រាយបំណុលដែលបានកម្ចីពីធនាគារឯកជន។ គាត់បានសម្តែងចេញពីចិត្តរបស់គាត់ថា "បើមើលពីសម្បកក្រៅ គឺឃើញខ្ញុំមានអារម្មណ៍សប្បាយចិត្តរីករាយរាល់ថ្ងៃ តែក្នុងចិត្តពោរពេញដោយទុក្ខព្រួយ ព្រោះគ្មានអ្នកទីពឹង គ្មានប្រាក់ចំណូលគ្រប់គ្រាន់ និងគ្មានផ្ទះស្នាក់នៅ។ ទាំងផ្ទះបងស្រី និងផ្ទះម្តាយត្រូវភ្លើងឆេះអស់នៅឯស្រុកកំណើត។"

តាមរយៈដំណើរជីវិតសិក្សារបស់និស្សិត វីរ៉ា ខាងលើ អាចលាតត្រដាងឱ្យយើងឃើញថា គាត់ជានិស្សិតម្នាក់ដែលត្រូវការលើកទឹកចិត្តខ្ពស់ទាំងផ្នែកស្មារតី និងធនធានថវិកាដោយសារគាត់ជាជនពិការ និងមិនមានសមាជិកគ្រួសារណាម្នាក់ជាគោលជំហរច្បាស់លាស់សម្រាប់ពឹងពាក់អាស្រ័យឡើយនៅអំឡុងពេលសិក្សា។

ភាពអត់ធ្មត់តស៊ូរហូតសម្រេចការសិក្សាមកដល់ពេលនេះ គឺតាមរយៈចេះផ្តល់កម្លាំងចិត្ត និងចេះបង្កើតការងារដោយខ្លួនឯង ជាពិសេសនោះគឺទឹកចិត្តគ្រូបង្រៀនតែម្តងដែលជាកត្តាលេចធ្លោជាងគេបំផុត។

ជាចុងបញ្ចប់ និស្សិតនារីម្នាក់នេះបានសុំអំពាវនាវដល់ក្រសួងពាក់ព័ន្ធនានា សប្បុរជនជិតឆ្ងាយ ជាពិសេសសាលារៀនតែម្តង សូមបន្តជួយផ្គត់ផ្គង់ការរៀនសូត្ររបស់គាត់ឱ្យបានដល់គោលដៅ។ ក្តីស្រមៃគាត់នាថ្ងៃអនាគត គឺគាត់ចង់មានការងារធ្វើល្អមួយ។

## ➢ និស្សិត លីម ស្រីនាង

និស្សិត លីម ស្រីនាង ក៏មិនខុសអ្វីពីនិស្សិតខាងលើដែរ ពីព្រោះអាហារូបករណ៍គឺជាចលករមួយដ៏សំខាន់បំផុតក្នុងផ្តល់ឱកាសអភិវឌ្ឍន៍សមត្ថភាពសម្រាប់អនាគតគាត់និងប្រទេសជាតិ។ ដោយសារការខិតខំប្រឹងប្រែងសិក្សា គាត់បានទទួលអាហារូបករណ៍សិក្សាថ្នាក់ឧត្តមសិក្សា បច្ចុប្បន្នស្រីនាងជានិស្សិតឆ្នាំទី១ ផ្នែកភាសាអង់គ្លេសនៅសាកលវិទ្យាល័យត្បូងឃ្មុំ។ គាត់ក៏ធ្លាប់ឆ្លងកាត់ជាសិស្សរៀនត្រួតថ្នាក់ និងធ្លាប់បោះបង់ការសិក្សាដែរ តែដោយសារការគិតគូពីឪពុកម្តាយ ធ្វើឱ្យគាត់សម្រេចចិត្តតស៊ូបន្តការសិក្សារហូតដល់បច្ចុប្បន្ន គាត់បានរៀបរាប់ថា "នៅថ្នាក់ទី៣ ខ្ញុំបានរៀនត្រួតថ្នាក់ម្តង ហើយចេះតែបន្តរៀនរហូតដល់ថ្នាក់ទី១០ ខ្ញុំក៏បានសម្រេចចិត្តបោះបង់ការសិក្សាចោល ពីព្រោះជីវភាពគ្រួសារជួបការលំបាកយ៉ាប់យឺនខ្លាំងពេក។ ខ្ញុំបានទៅធ្វើការជាអ្នកបេះម្រេចប្រហែលជាកន្លះឆ្នាំដែរ តែដោយសារការអាណិត និងការទទូចរបស់ឪពុកម្តាយ ធ្វើឱ្យខ្ញុំសម្រេចចិត្តចូលរៀនវិញ។" ជីវភាពពិតជាអាចធ្វើឱ្យស្រីនាងហ៊ានបោះបង់ការសិក្សា និងលុបបំបាត់ឱកាសខ្លួនឯងដើម្បីក្លាយជាធនធានមួយរូបដែលអាចលះបង់ចំណេះដឹងដើម្បីអភិវឌ្ឍន៍សង្គមបាន តែដោយសារតែទឹកចិត្តឪពុកម្តាយធំធេងពេក មិនអាចអនុញ្ញាតឱ្យជីវភាពជារបាំងរារាំងឱកាសការសិក្សាកូនបានឡើយ។ ទោះបីក្នុងកាលៈទេសៈលំបាកយ៉ាងណាក៏ដោយ ក៏លោកទាំងពីរតស៊ូដើម្បីកូន និងខំប្រឹងអូសទាញកូនមកចូលរៀនវិញ កុំអីកម្ពុជាត្រូវបាត់បង់ធនធានម្នាក់នេះបាត់ទៅហើយ ស្រីនាងបានលើកឡើងថា "គាត់ស៊ូលំបាកឱ្យតែខ្ញុំបានចូលរៀនវិញ។" តាមរយៈនេះអាចបញ្ជាក់បានថា កត្តាឪពុកម្តាយគឺជាផ្នែកមួយដ៏មានឥទ្ធិពលបំផុតក្នុងការចូលរួមសម្រេចភាពជោគជ័យនៃការសិក្សារបស់កូន និងការលុបបំបាត់អត្រាបោះបង់ការសិក្សារបស់សិស្ស។ ការបណ្តុះផ្នត់គំនិតក្តីស្រឡាញ់ និងជំនឿចិត្តរបស់ឪពុកម្តាយចំពោះវិស័យអប់រំ គឺជាការកសាងសង្គមពុទ្ធិមួយប្រកបដោយប្រសិទ្ធភាព។ បន្ថែមពីនេះទៀត និស្សិត លីម ស្រីនាង ក៏មានជំនឿចិត្តថា មានតែការសិក្សាទេដែលអាចជួយគាត់ឱ្យរួចផុតពីទុក្ខលំបាក ដូចដែលគាត់បាននិយាយថា "មានតែការសិក្សាមានចំណេះដឹងទើបគេចផុតពីភាពលំបាកក្រខ្សត់។ ហើយគាត់បានសង្កត់ធ្ងន់ថា បើខ្ញុំឈប់រៀន ខ្ញុំនឹងលំបាក ហើយលំបាកដល់ឪពុកម្តាយថែមទៀត តែបើខ្ញុំរៀនវិញ គឺលំបាកតែពេលឪពុកម្តាយរកលុយឱ្យរៀនប៉ុណ្ណោះ ដល់ពេលខ្ញុំរៀនយូរទៅ ខ្ញុំនឹងអាចធ្វើការ និងជួយឪពុកម្តាយវិញ។"

កម្រិតការអប់រំរបស់ឪពុកម្តាយស្រីនាងបានរៀនសូត្រត្រឹមថ្នាក់ទី១ប៉ុណ្ណោះ ឪពុកជាអ្នកលើកអុសដាក់ឡានបានប្រាក់កម្រៃ ១៥០០០ ទៅ ២០០០០រៀលក្នុងមួយថ្ងៃ រីឯម្តាយវិញជាអ្នកធ្វើការនៅរោងចក្រកែច្នៃដំណាប់ស្វាយទទួលបានប្រាក់ខែ ៦០ម៉ឺនរៀលក្នុងមួយខែ។ ឪពុកម្តាយរបស់ស្រីនាងមានលទ្ធភាពផ្តល់ប្រាក់ឧបត្ថម្ភឱ្យកូនប្រហែល ៥ម៉ឺនរៀលក្នុងមួយខែសម្រាប់ការចំណាយទូទៅលើការសិក្សា

ដូចជា៖ ម្ហូបអាហារ សម្ភារសិក្សា សំលៀកបំពាក់ ថ្លៃធ្វើដំណើរ។ល។ ចំណែកការស្នាក់នៅមិនត្រូវបានចំណាយទេ ដោយសារមានការផ្តត់ផ្គង់ពីសាកលវិទ្យាល័យ ប៉ុន្តែស្រីនាងបានបង្ហាញក្តីកង្វល់ថា "នៅពេលខាងមុខ សាលាតម្រូវឱ្យសិស្ស ម្នាក់ៗជួយបង់ថ្លៃអនាម័យនិងសន្តិសុខចំនួន១ម៉ឺនរៀលក្នុងមួយខែ។" ដោយមើលឃើញឪពុកម្តាយលំបាកក្នុងការរកលុយឱ្យគាត់រៀននិងមានជីវភាពគ្រួសារជួបការខ្វះខាតខ្លាំងពេក ស្រីនាងចំណាយលុយត្រឹម១ពាន់រៀលក្នុងមួយថ្ងៃជាមួយមិត្តរួមបន្ទប់ (៨រូប) សម្រាប់អាហារប្រចាំថ្ងៃប៉ុណ្ណោះ។ ស្ថិតក្នុងគ្រួសារដែលមានជីវភាពមិនសូវស្តុកស្តម្ភ ស្រីនាងទទួលស្គាល់ខ្លួនឯងថា នាងមិនមានសុខភាពល្អបរិបូរណ៍ដោយសារការបរិភោគមិនគ្រប់គ្រាន់ធ្វើឱ្យសុខភាពនាងខ្សោយនិងធាប់ហាត់។

ជាចុងបញ្ចប់ និស្សិត លីម ស្រីនាង ទទូចសុំការឧបត្ថម្ភបន្ថែមរួមទាំង ម្ហូបអាហារ សម្ភារសិក្សា ថវិកាសំលៀកបំពាក់ និងសុំកុំយកថ្លៃផ្ញើកង់ម៉ូតូ ដោយសារម្តាយរបស់ស្រីនាងមានលទ្ធភាពផ្តល់ឱ្យកូនប្រហែល៥ម៉ឺនរៀលក្នុងមួយខែ។ ចំពោះអនាគតវិញ ស្រីនាងសង្ឃឹមថា គាត់នឹងអាចរកបានការងារល្អធ្វើ គាត់នឹងជួយបណ្តុះបណ្តាលក្មេងៗឱ្យខិតខំរៀនសូត្រឱ្យមានចំណេះដឹងខ្ពង់ខ្ពស់ដើម្បីជួយដល់សង្គម។

## ៥. សេចក្តីសន្និដ្ឋាន

ការសិក្សានេះដើម្បីស្វែងយល់ពីជីវិតការសិក្សា និងការរស់នៅនៃនិស្សិតនារីនៅកម្រិតថ្នាក់ឧត្តមសិក្សា ដោយប្រើវិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យពេលចុះប្រមូលទិន្នន័យតាមសាលា។ ឆ្លងតាមអ្នកស្រាវជ្រាវបានរកឃើញថា ទន្ទឹមនឹងការទទួលបានឱកាស និស្សិតនារីក៏មានបញ្ហាប្រឈមជាច្រើនក្នុងអំឡុងពេលសិក្សា ដូចជា កង្វះអាហារូបត្ថម្ភ កង្វះអគារអន្តេវាសិកដ្ឋាន និងការថែទាំអនាម័យក្នុងបន្ទប់ ការទទួលរងបន្ទុកគ្រួសារ បញ្ហាសុខភាព កង្វះសេវាផ្តល់ប្រឹក្សាក្នុងសាលា។ ដើម្បីដោះស្រាយជីវភាពក្នុងអំឡុងពេលសិក្សា និស្សិតនារីភាគច្រើនបានអនុវត្តន៍ "រៀនបណ្តើរ ធ្វើការបណ្តើរ" រហូតដល់មាននិស្សិតខ្លះអាចឈានទៅដល់ការផ្ញើប្រាក់ជូនក្រុមគ្រួសារថែមទៀត។ ជាការកត់សម្គាល់ឧបសគ្គធំបំផុតដែលបង្កឱ្យសិស្សនារីអាចឈានទៅរកការបោះបង់ការសិក្សា គឺកត្តាជីវភាពក្រីក្រតែម្តង ដូច្នេះការកាត់បន្ថយភាពក្រីក្រ ក៏មានន័យជាការចូលរួមចំណែកលើកកម្ពស់គុណភាពអប់រំដល់សិស្សនារីផងដែរ។ លើសពីនេះ ទឹកចិត្តគ្រូបង្រៀនបានដើរតួយ៉ាងសំខាន់ដូចនឹងពាក្យថា "គ្រូបង្រៀនជាវិស្វករព្រលឹង" ក្នុងការបណ្តុះស្មារតី ការលើកទឹកចិត្ត និងការទំនុកបម្រុងក្នុងដំណើរភាពជោគជ័យនៃការសិក្សារបស់សិស្សនារីនៅពេលមានបញ្ហាប្រឈមនៃភាពអស់សង្ឃឹម និងការបាក់ទឹកចិត្តជាដើម។ ជាសន្និដ្ឋានរួម កាលណាកម្រិតជីវភាពឪពុកម្តាយកាន់តែលំបាក និស្សិតនារី នឹងទទួលរងផលប៉ះពាល់ពីសម្ពាធគ្រួសារកាន់តែធ្ងន់ ហើយចុងក្រោយអាចឈានទៅរកការបោះបង់សិក្សា។ ជាអនុសាសន៍

ចំពោះការកែលម្អ និងសាងសង់អគារអន្តេវាសិកដ្ឋាន៖ ពង្រឹង និងពង្រីកគោលនយោបាយនៃការបន្ត អភិវឌ្ឍការកសាងអគារអន្តេវាសិកដ្ឋានក្នុងសាកលវិទ្យាល័យ ដើម្បីសម្រួលបន្ទុកនៃការចំណាយរបស់និស្សិត និងកាត់បន្ថយក្តីបារម្ភពីសំណាក់ឪពុកម្តាយក្នុងអំឡុងពេលសិក្សា។ ចំនួននិស្សិតស្នាក់នៅគួរតែរៀបចំត្រឹម៤រូប ឬ៦រូបច្រើនបំផុតក្នុងមួយបន្ទប់ ហើយគួរបំពាក់គ្រែដែលមានពីរជាន់(ថ្នាក់) ដើម្បីសន្សំទីកន្លែង និងសម្រួលដល់និស្សិតធ្វើស្វ័យសិក្សា។ ក្រសួងអប់រំគួរពិចារណាសិក្សាលទ្ធភាពក្នុងការតម្លើងប្រាក់អាហារូបករណ៍ជូនដល់និស្សិត បើក្រសួងមិនមានលទ្ធភាពតម្លើងប្រាក់អាហារូបករណ៍ដល់និស្សិតទាំងអស់ទេ (១០០%) ជាទស្សនអ្នកស្រាវជ្រាវគឺសុំត្រឹមនិស្សិតអាហារូបករណ៍នារី (១៥%) និស្សិតជួបការលំបាក (២០%) និងតំបន់ដាច់ស្រយាល (៥%) ដើម្បីលើកកម្ពស់សុខភាពរស់នៅ និងការអប់រំដល់ប្រជាពលរដ្ឋ។ តាមទស្សនៈនិស្សិតនារីម្នាក់សំណើសុំតម្លើងរហូតដល់ចំនួន ១៥ ម៉ឺនរៀល ពីលើប្រាក់ខែបច្ចុប្បន្នក្នុងមួយខែ ចំណែកទស្សនៈសាកលវិទ្យាធិការ(រង) និងសាស្ត្រាចារ្យទទួលបន្ទុកសំណើសុំតម្លើងរហូតដល់ ២០ម៉ឺន ទៅ ២៨ម៉ឺនរៀល ក្នុងមួយខែ។

## ឯកសារយោង

Birrell, B., Calderon, A., Dobson, I.R. &Smith, T.F. (2000). Equity in access to higher education revisited. People and Plance, 8 (1), 50-61

Chea, V. (2009) Reaching the unreached: Briding the social divide in Cambodia through inclusive education. Paper presented at the 12th UNESCO-APEID International Conference, Bankok, Thailand. Retrieved from http://www.vso.nl/Images/reaching-the-unreached_tcm80-23047.pdf

Escamilla, Monica. (2011). NGO Education and the Development of Civil Society in Cambodia: Enculturation and Grassroots Post-conflict Reconstruction. Canada: Lambert AcademicPublishing.

EMIS. (2016). Education Statistics and Indicator in Cambodia 2006-2016. Ministry of Education, Youth and Sport. Phnom Penh.

Patricia Noelle O'Brien (2004), Challenges to higher education in Cambodia: access, equity of access and quality & relevance. Available from: http://119.82.251.165:8080/xmlui/handle/123456789/207 [Accessed on 25 November 2019]

Shan-shan Wang, Sovichea Lay, Hai-ning Yu, & Sheng-rong Shen (2016), Dietary Guidelines for Chinese Residents (2016): comments and comparisons, J Zhejiang Univ Sci B. 2016 Sep; 17(9): 649–656

UNDP (2009). Gender. Retrieved from http://www.undp.org.ir/index.php/gender UNESCO (2007) Global education digest 2007: Comparing education statistics across the world. Montreal: UNESCO Institute of Statistics.

# ឧបសម្ព័ន្ធ




**រូបភាព៖** ទម្រង់ផ្សេងៗនៃការបំពាក់គ្រែពីរជាន់ (ថ្នាក់) ក្នុងបន្ទប់អន្តេវាសិកដ្ឋានសម្រាប់និស្សិតស្នាក់នៅ៖ រូបភាព (A, B, C) មានទម្រង់គ្រែគេងប្រហាក់ប្រហែលគ្នា ដោយសារតែគ្រែជាន់ខាងលើសម្រាប់និស្សិតគេង និងខាងក្រោមសម្រាប់និស្សិតធ្វើស្វ័យសិក្សា ព្រមទាំងមានទូរសម្រាប់ដាក់សំលៀកបំពាក់រៀងៗខ្លួនថែមទៀត។ ចំណែករូបភាព (D) ទម្រង់គ្រែគេងគឺសម្រាប់និស្សិតពីររូបតែម្តង ដោយម្នាក់តម្រូវឱ្យគេងខាងលើ និងម្នាក់ទៀតតម្រូវឱ្យគេងខាងក្រោម ហើយតុអង្គុយស្វ័យសិក្សាត្រូវបានរៀបចំដាច់ដោយឡែកពីគ្នា។